

# របាយការណ៍

# វេទិកាជាតិលើកទី២ ស្តីពី ទីក្រុង និងលំនៅឋាន

ក្រោមមូលបទ "ទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ន"

ថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៤

រាជធានីភ្នំពេញ កម្ពុជា


VISA

# មាតិកា


*អក្សរកាត់* *i*

*បុព្វកថា* *ii*

*១. ទិដ្ឋភាពរួមទូទៅ* *1*

ព័ត៌មានសាវតារ **1**

គោលបំណង និងលទ្ធផលរំពឹងទុក **1**

កម្មវិធី **2**

សេចក្ដីសង្ខេបអំពីអ្នកចូលរួម **2**

*២. សេចក្ដីសង្ខេបវគ្គនិមួយៗ (ថ្ងៃទី១)* *5*

វគ្គទី១៖ ការបើកវេទិកា **5**

វគ្គទី២៖ បទបង្ហាញដោយអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម **8**

វគ្គទី៣៖ បទបង្ហាញដោយដៃគូអភិវឌ្ឍន៍ និងកិច្ចពិភាក្សា **11**

*៣. សេចក្ដីសង្ខេបវគ្គនិមួយៗ (ថ្ងៃទី២)* *16*

វគ្គទី៤៖ ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យនៅកម្ពុជា **16**

វគ្គទី៥៖ បទបង្ហាញដោយបេក្ខជនជ័យលាភីនៃកម្មវិធីប្រឡងប្រណាំងស្នាដៃសិក្សារចនាទីក្រុង **20**

វគ្គទី៦៖ កម្មវិធីបិទវេទិកា **24**

*ឧបសម្ព័ន្ធ* *27*

ឧបសម្ព័ន្ធ១៖ របៀបវារៈនៃវេទិកាជាតិលើកទី២ស្ដីពី"ទីក្រុង និងលំនៅឋាន" **28**

ឧបសម្ព័ន្ធ ២៖ បញ្ជីអ្នកចូលរួម **31**

ឧបសម្ព័ន្ធ ៣៖ រូបថត **34**

ឧបសម្ព័ន្ធ ៤៖ ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ **39**

ឧបសម្ព័ន្ធ ៥៖ សេចក្ដីប្រកាសព័ត៌មាន៖ វេទិកាជាតិលើកទី២ ស្ដីពី "ទីក្រុង និងលំនៅឋាន" **40**

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) |
| ATM | ម៉ាស៊ីនដក-ដាក់ប្រាក់ស្វ័យប្រវត្តិ |
| AR | បច្ចេកវិទ្យា AR (Augmented Reality) |
| CUHF 2 | វេទិកាជាតិលើកទី២ ស្ដីពី "ទីក្រុង និងលំនៅឋាន" |
| DPM | ឧបនាយករដ្ឋមន្ត្រី |
| GDLMUP | អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម |
| GDP | ផលិតផលក្នុងស្រុកសរុប |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MoI | ក្រសួងមហាផ្ទៃ |
| NBS | ដំណោះស្រាយផ្អែកលើធម្មជាតិ |
| NSCS | យុទ្ធសាស្ត្រទីក្រុងឆ្លាតថ្នាក់ជាតិ |
| QR code | QR កូដ (Quick-Response Code) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| UNESCAP | គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក |
| UNOPS | ការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោង |
| UN-Habitat | កម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ |
| VR | បច្ចេកវិទ្យា VR (Virtual Reality) |

# បុព្វកថា

## បុព្វកថា



ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ កម្ពុជាមាននិកាសជាថ្មីក្នុងការស្តារ និងកសាងប្រទេសឡើងវិញពីបាតដៃទទេចេញពីសមុទ្រឈាម គំនរឆ្អឹង និងផេះផង់នៃសង្គ្រាមរហូតទទួលបានសមិទ្ធផលដ៏ថ្លៃថ្លាដូចដែលយើងទាំងអស់គ្នាបានឃើញច្បាស់នៅពេលនេះ។ សមិទ្ធផលទាំងនេះបានផ្តើមចេញពីការដឹកនាំ និងអនុវត្តប្រកបដោយជោគជ័យនូវ ***នយោបាយឈ្នះ-ឈ្នះ*** នៅឆ្នាំ ១៩៩៨ ដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានលុបបំបាត់នូវព្រំដែនផ្ទៃក្នុងរបស់ប្រទេស ហើយបាននាំមកនូវសុខសន្តិភាព ស្ថិរភាពនយោបាយពេញលេញជូនដល់ប្រជាជាតិយើង និងផ្តល់និកាសដល់ការវិនិយោគ និងការអភិវឌ្ឍលើគ្រប់វិស័យទូទាំងប្រទេស។

រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងជំរភាពរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ"**យុទ្ធសាស្ត្របញ្ចកោណ**" ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះទៅសម្រេចបានចក្ខុវិស័យកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយកំណត់យកជាវិស័យអាទិភាព៥គឺ "**មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា**" ក្នុងការកសាង "**សង្គមជាតិកម្ពុជាសហសម័យ**" ឈរលើមូលដ្ឋានសន្តិភាព នីតិរដ្ឋ ប្រជាធិបតេយ្យសេរីពហុបក្ស និងកសាងសេដ្ឋកិច្ចដើម្បីឱ្យមានការរីកចម្រើនសំដៅធ្វើឱ្យប្រជាជនមានជីវភាពកាន់តែល្អប្រសើរ ទាំងមូលដ្ឋានសម្ភារៈ គំនិត និងមនសិការជាតិ។

ក្នុងគោលដៅបន្តពូនជ្រំនូវសមិទ្ធផលរបស់រាជរដ្ឋាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បន្តធ្វើទំនើបកម្មស្ថាប័ន ពូនជ្រំរដ្ឋបាលសាធារណៈទំនើប និងបន្តកំណែទម្រង់អភិបាលកិច្ច និងហិរញ្ញវត្ថុសាធារណៈប្រកដោយប្រសិទ្ធភាព និងគណនេយ្យភាពដើម្បីជាខឿនទ្រទ្រង់ដំណើរការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅក្នុងបញ្ចកោណទី៤នៃយុទ្ធសាស្ត្របញ្ចកោណ "ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន" បានកំណត់នូវមុំទី៤ "**ការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្ម**" ដែលរាជរដ្ឋាភិបាលផ្តោតលើការងារអាទិភាពចំនួន៥ និងកំណត់នូវគោលដៅយុទ្ធសាស្ត្រនៃការពង្រីកទីក្រុង ការអភិវឌ្ឍទីក្រុងថ្មីៗបន្ថែមនៅតាមបណ្តារាជធានី ខេត្ត ការបង្កើតសួនសាធារណៈ និងឧទ្យានបៃតង និងការពង្រឹងការគ្រប់គ្រង និងការធ្វើទំនើបកម្មនគរូបនីយកម្មដើម្បីធានាសុវត្ថិភាព សោភណភាព បរិស្ថានល្អ និងសុខុមាលភាពសម្រាប់ការរស់នៅ និងប្រសិទ្ធភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវ **គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ដោយបានកំណត់ចក្ខុវិស័យថា "ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យល្អនូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ" និងដាក់ចេញនូវ **គោលនយោបាយជាតិស្តីពីលំនៅឋាន** ដែលមានចក្ខុវិស័យធ្វើឱ្យប្រជាជនទូទាំងប្រទេសមានលំនៅឋានសមរម្យ

អាចរស់នៅបានប្រកបដោយសុខុមាលភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ជាពិសេសប្រជាពលរដ្ឋមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានសហការជាមួយធនាគារពិភពលោក និងតំណាងការិយាល័យសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជាក្នុងការរៀបចំវេទិកាជាតិលើកទី២ ស្តីពី **"ទីក្រុងនិងលំនៅឋាន"** កាលពីថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៤ ក្នុងគោលបំណងតម្រង់ទិសចក្ខុវិស័យរបស់កម្ពុជាសម្រាប់ទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ន តាមរយៈយុទ្ធសាស្ត្រជាតិស្តីពីទីក្រុង និងជាវេទិកាសម្រាប់ពិភាក្សានិងផ្លាស់ប្តូរយោបល់លើមធ្យោបាយផ្សេងទៀតសម្រាប់ការដោះស្រាយបញ្ហាអាទិភាពក្នុងទីក្រុងសំខាន់ៗដែលបានឯកភាពរួច រួមមានកិច្ចអន្តរាគមន៍ផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានាដែលផ្តោតសំខាន់លើការអភិវឌ្ឍសមត្ថភាព នវានុវត្តន៍ ការសម្របសម្រួល និងភាពជាដៃគូជាយុទ្ធសាស្ត្ររួមទាំងវិស័យឯកជន ការវិនិយោគលើទីក្រុងឆ្លាត សំណង់មិនរៀបរយក្នុងទីក្រុង ការរចនាទីក្រុង និងការរៀបចំគម្រោងនានាសម្រាប់ទាក់ទាញការវិនិយោគ។

ខ្ញុំសង្ឃឹមជឿជាក់ថារបាយការណ៍ស្តីពីវេទិកាជាតិលើកទី២ ស្តីពី **"ទីក្រុងនិងលំនៅឋាន"** នេះនឹងក្លាយជាផ្នែកមួយនៃធាតុចូលដែលជួយតម្រង់ទិស និងគាំទ្រដល់ការអនុវត្តគោលនយោបាយអាទិភាពក្នុងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងលំនៅឋាន និងសូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយធនាគារពិភពលោក និងអង្គការសហប្រជាជាតិនាពេលកន្លងទៅ ព្រមទាំងស្វាគមន៍ក្នុងការបន្តកិច្ចសហប្រតិបត្តិការនេះឱ្យកាន់តែល្អប្រសើរបន្ថែមទៀតដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០។

ថ្ងៃអង្គារ ១១កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**



# ១. ទិដ្ឋភាពរួមទូទៅ

## ព័ត៌មានសាវតារ

កំណើននគរូបនីយកម្មនៅកម្ពុជាមានល្បឿនគួរឱ្យកត់សម្គាល់។ ការព្យាករណ៍បង្ហាញថា នៅឆ្នាំ២០៣០ ប្រជាជនកម្ពុជាប្រមាណជា១ភាគ៣នឹងរស់នៅក្នុងទីក្រុង ដែលកត្តានេះនឹងនាំឱ្យមានបញ្ហាប្រឈមជាច្រើនក្នុងការពង្រីកសេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុងឱ្យស្របនឹងកំណើនប្រជាជន។ ទន្ទឹមនឹងនេះ កំណើននគរូបនីយកម្មក៏នឹងនាំឱ្យមានសម្ពាធលើបរិស្ថាន និងការប្រើប្រាស់ដី។ ដូច្នេះ ទស្សនវិស័យនៃការអភិវឌ្ឍប្រទេសនឹងពឹងផ្អែកកាន់តែខ្លាំងលើការរៀបចំទីក្រុង និងទីប្រជុំជន។ លោក បាន គីមូន អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ ធ្លាប់បានលើកឡើងថា "ការខំពុះពាររបស់យើងសម្រាប់ចីរភាពពិភពលោកអាចនឹងទទួលបានជោគជ័យ ឬបរាជ័យនៅក្នុងទីក្រុង"។ ទីក្រុងនឹងកំណត់លើការសម្រេចបាននៃការអភិវឌ្ឍប្រកបដោយចីរភាពនៅឆ្នាំ២០៣០។ ស្ថានភាពនេះអំពាវនាវឱ្យមានដំណោះស្រាយថ្មីៗ។

ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ និងគ្រោះមហន្តរាយទៅក្នុងសេចក្តីសម្រេចលើការវិនិយោគ ជាធាតុផ្សំចម្បងសម្រាប់នគរូបនីយកម្មបៃតង ឬប្រកបដោយចីរភាព។ សន្ទស្សន៍ហានិភ័យអាកាសធាតុឆ្នាំ២០២០ បានដាក់ចំណាត់ថ្នាក់កម្ពុជានៅលេខរៀងទី២១ ក្នុងចំណោម១៧២ប្រទេសដែលងាយរងគ្រោះដោយសារគ្រោះមហន្តរាយ អំឡុងឆ្នាំ១៩៩៩-២០១៨។ ផ្ទៃដីប្រមាណ៨០%នៅកម្ពុជាស្ថិតក្នុងអាងទន្លេមេគង្គ និងទន្លេសាប ជាហេតុធ្វើឱ្យកម្ពុជាងាយរងគ្រោះដោយសារទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត ដែលរំពឹងថានឹងកើនឡើងកាន់តែជាក់ច្បាស់ និងធ្ងន់ធ្ងរក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ តម្រូវការចាំបាច់សម្រាប់ការវិនិយោគក្នុងទីក្រុងនៅកម្ពុជា គឺត្រូវពិចារណាពីហានិភ័យអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយដែលកំពុងជួបប្រទះ និងអាចកើតមាននាពេលអនាគត ដោយបញ្ចៀសការអភិវឌ្ឍពីតំបន់មានហានិភ័យខ្ពស់តាមរយៈការប្រើប្រាស់ដីសមស្រប ការកាត់បន្ថយហានិភ័យរូបវន្តតាមរយៈការរចនា ការសាងសង់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុងឱ្យបានត្រឹមត្រូវ ព្រមជាមួយនឹងការពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួល។

នគរូបនីយកម្មអាចដើរតួនាទីជាវិជ្ជមាន ជាជាងផលវិបាកដែលចាំបាច់ត្រូវរៀបចំ ប្រសិនបើតួអង្គផ្សេងៗអាចចូលរួមជាមួយគ្នាតាមរយៈវេទិកាមួយដើម្បីលុបបំបាត់ភាពបែកខ្ញែក និងបង្កើនសកម្មភាពប្រទាក់ក្រឡាគ្នា។ វេទិកាជាតិលើកទី២ស្តីពី "ទីក្រុង និងលំនៅឋាន" ផ្តល់ជាវេទិកាមួយសម្រាប់កិច្ចសន្ទនាពហុភាគីក្នុងការពិភាក្សា និងឯកភាពគ្នាលើគោលនយោបាយប្រទាក់ក្រឡា អាទិភាពជាយុទ្ធសាស្ត្រ និងអាទិភាពកម្មវិធី ឆ្ពោះទៅរកការអភិវឌ្ឍទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ន។ វេទិកានេះនឹងផ្តល់ឱកាសដល់ការរៀបចំធាតុចូលដែលមានលក្ខណៈសម្របសម្រួលសម្រាប់ដំណើរការតាមដានបន្ត និងការពិនិត្យឡើងវិញលើរបៀបវារៈអភិវឌ្ឍន៍សកល ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals) (ជាពិសេស គោលដៅទី១១) និងរបៀបវារៈទីក្រុងថ្មី (New Urban Agenda) ដោយផ្អែកលើកិច្ចការដែលកម្ពុជាបានធ្វើរួចមកហើយជាមួយនឹងរបាយការណ៍ថ្នាក់ជាតិ (Habitat III) និងក្រោមក្របខណ្ឌជំនួយអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ២០១៩-២០២៣។

## គោលបំណង និងលទ្ធផលរំពឹងទុក

វេទិកាជាតិលើកទី២ ស្តីពី "ទីក្រុង និងលំនៅឋាន" បានរៀបចំឡើងនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៤ ក្រោមកិច្ចសហការរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធនាគារពិភពលោក និងកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UN-Habitat) ។ ភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិជាង ៣០០រូបបានចូលរួមនៅក្នុង

ព្រឹត្តិការណ៍នេះ និងបានពិភាក្សាគ្នាក្រោមមូលបទ "ទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ន"។

ដើម្បីសម្រេចបានគោលបំណង និងលទ្ធផលរំពឹងខាងក្រោម វេទិកាជាតិលើកទី២នេះមានប្រាំមួយវគ្គសំខាន់ៗក្នុងទិសដៅកំណត់ឱ្យបាននូវអាទិភាពទីក្រុង ព្រមទាំងពិភាក្សា និងឯកភាពគ្នាលើមធ្យោបាយសម្រាប់ដោះស្រាយ ហើយសំដៅបង្កើតទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ននៅកម្ពុជា។

**<u>គោលបំណង</u>**

- បង្កើតវេទិកាពិភាក្សាស្តីពីអាទិភាពទីក្រុង សំដៅតម្រង់ទិសចក្ខុវិស័យរបស់កម្ពុជាសម្រាប់ទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ន តាមរយៈយុទ្ធសាស្ត្រជាតិស្តីពីទីក្រុង។
- ពិភាក្សា និងឯកភាពគ្នាលើមធ្យោបាយផ្សេងទៀតសម្រាប់ដោះស្រាយអាទិភាពទីក្រុងសំខាន់ៗដែលបានឯកភាពរួច រួមមានកិច្ចអន្តរាគមន៍ផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានាដែលផ្តោតសំខាន់លើការអភិវឌ្ឍសមត្ថភាព នវានុវត្តន៍ ការសម្របសម្រួល និងភាពជាដៃគូជាយុទ្ធសាស្ត្រ រួមទាំងវិស័យឯកជន ការវិនិយោគលើទីក្រុងឆ្លាត សំណង់មិនរៀបរយក្នុងទីក្រុង ការរចនាទីក្រុង និងការរៀបចំគម្រោងនានាដែលទាក់ទាញការវិនិយោគ។

**<u>លទ្ធផលរំពឹងទុក</u>**

- សេចក្តីថ្លែងការណ៍ពីចក្ខុវិស័យរបស់កម្ពុជាសម្រាប់ការអភិវឌ្ឍទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ន។ ចក្ខុវិស័យនេះត្រូវភ្ជាប់មកជាមួយនឹងសេចក្តីថ្លែងការណ៍ពីលទ្ធផលរំពឹងទុក។
- អាទិភាពទីក្រុងសំខាន់ៗដែលបានឯកភាពក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានាសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។
- មធ្យោបាយស្នើឡើងសម្រាប់ដោះស្រាយអាទិភាពទីក្រុងសំខាន់ៗ ដែលត្រូវបានកំណត់តាមក្របខណ្ឌពេលវេលាតាមកិច្ចការរបស់ស្ថាប័នដឹកនាំដើម្បីអនុវត្តកិច្ចការអាទិភាពបន្ត ដែលរួមមានគោលនយោបាយស្តីពីទីក្រុងឆ្លាត និងយុទ្ធសាស្ត្រជាតិស្តីពីទីក្រុង។

## កម្មវិធី

វេទិកាជាតិលើកទី២ស្តីពី "ទីក្រុង និងលំនៅឋាន" មានរយៈពេលពីរថ្ងៃ និងបែងចែកជាប្រាំមួយវគ្គ ។

**<u>ថ្ងៃទីមួយ - ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤</u>**

វេទិកាបើកដំណើរការជាមួយនឹងសុន្ទរកថាបើកវេទិកាពីតំណាងមកពីស្ថាប័នដែលដឹកនាំក្នុងវិស័យនគរូបនីយកម្ម និងលំនៅឋាននៅកម្ពុជា។ នៅក្នុងវគ្គទី២ តំណាងមកពីអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម បានបង្ហាញពីទិដ្ឋភាពទូទៅអំពីស្ថានភាពបច្ចុប្បន្ននៃការរៀបចំដែនដី ក្របខណ្ឌច្បាប់ និងគតិយុត្តពាក់ព័ន្ធនឹងនគរូបនីយកម្ម និងករណីសិក្សាចំនួនបី នៅកម្ពុជា។ នៅវគ្គទី៣ តំណាងមកពីស្ថាប័នអន្តរជាតិ និងដៃគូអភិវឌ្ឍន៍បានចែករំលែកបទពិសោធន៍ និងរបកគំហើញពាក់ព័ន្ធនឹងទីក្រុងឆ្លាត និងប្រកបដោយចីរភាព ដំណោះស្រាយផ្អែកលើធម្មជាតិ និងការរៀបចំដែនដី។

**<u>ថ្ងៃទីពីរ - ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤</u>**

ថ្ងៃទីពីរនៃវេទិកានេះបានចាប់ផ្តើមជាមួយវគ្គទី៤ពាក់ព័ន្ធនឹងស្ថានភាពនាពេលបច្ចុប្បន្ន និងការអនុវត្តល្អៗស្តីពីលំនៅឋានតម្លៃសមរម្យ។ នៅក្នុងវគ្គទី៥ បេក្ខជនទទួលជ័យលាភីក្នុងកម្មវិធីប្រឡងប្រណាំងស្នាដៃសិក្សាគម្រោងរចនាទីក្រុងបានធ្វើបទបង្ហាញអំពីគំនិតរបស់ពួកគេក្នុងការកែលម្អការរចនាទីក្រុងនៅក្នុងដែលទីតាំងមួយចំនួនដែលបានជ្រើសរើសនៅរាជធានីភ្នំពេញ។ វេទិកានេះបានបូកសរុបដោយសុន្ទរកថាបិទវេទិកាដែលជំរុញបន្តភាពជាដៃគូរបស់ភាគីពាក់ព័ន្ធ ដើម្បីសម្រេចឱ្យបានការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព និងបរិយាបន្ន សម្រាប់ប្រជាជនគ្រប់រូបនៅកម្ពុជា។ របៀបវារៈលម្អិតមាននៅក្នុងឧបសម្ព័ន្ធ១។

## សេចក្តីសង្ខេបអំពីអ្នកចូលរួម

ដូចការបង្ហាញនៅក្នុងឧបសម្ព័ន្ធ២ អ្នកចូលរួមចំនួន៣០០រូបបានចូលរួមនៅក្នុងវេទិកាជាតិលើកទី២ ស្តីពី "ទីក្រុង និងលំនៅឋាន"។

វេទិកាជាតិលើកទី២ ស្តីពី
"ទីក្រុង និងលំនៅឋាន"

| ប្រភេទ | ចំនួនអ្នកចូលរួម |
|---|---|
| ក្រសួង និងស្ថាប័នរដ្ឋាភិបាល | ១៣៥រូប |
| មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានី ខេត្ត | ៣៣រូប |
| រដ្ឋបាលរាជធានី ខេត្ត | ២៤រូប |
| ទីភ្នាក់ងារអង្គការសហប្រជាជាតិ | ១៣រូប |
| ដៃគូអភិវឌ្ឍន៍ | ១៦រូប |
| ស្ថានទូតបរទេស | ៥រូប |
| អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល | ១១រូប |
| គ្រឹះស្ថានអប់រំ និងស្រាវជ្រាវ | ៤៧រូប |
| វិស័យឯកជន | ១៤រូប |
| ប្រព័ន្ធផ្សព្វផ្សាយ | ២រូប |
| សរុប | ៣០០រូប |



# សេចក្ដីសង្ខេបវគ្គនិមួយៗ

# ២. សេចក្តីសង្ខេបវគ្គនិមួយៗ (ថ្ងៃទី១)

## វគ្គទី១៖ ការបើកវេទិកា




វេទិកានេះបានចាប់ផ្តើមជាមួយនឹងសុន្ទរកថាបើកវេទិកាដោយ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តំណាងUN-Habitat និងធនាគារពិភពលោក។

### វាគ្មិន

- **លោក** Srinivasa POPURI ប្រធានកម្មវិធីទីក្រុងបាងកក ការិយាល័យកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក
- **លោកស្រី** Maryam Salim ប្រធានធនាគារពិភពលោកប្រចាំកម្ពុជា
- **ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ** អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម (GDLMUP)
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)

### សេចក្តីសង្ខេប

**លោក Srinivasa POPURI ប្រធានកម្មវិធីទីក្រុងបាងកក ការិយាល័យកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក**

លោកPopuriបានបើកវេទិកានេះដោយលើកឡើងពីសារៈសំខាន់នៃការរៀបចំផែនការរួមដែលជាមូលដ្ឋាននៃគោលនយោបាយជាតិស្តីពីនគរូបនីយកម្ម ការចែករំលែកចក្ខុវិស័យរួមសម្រាប់ការដោះស្រាយអាទិភាពសំខាន់ៗសំដៅបង្កើតទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្នកាន់តែច្រើននៅទូទាំងប្រទេសកម្ពុជា។ លោកក៏បានសង្កត់ធ្ងន់ថា វេទិកាជាតិលើកទី២នេះផ្តល់ឱកាសសម្រាប់កិច្ចសន្ទនារវាងភាគីពាក់ព័ន្ធ ដើម្បីឯកភាពគ្នាលើគោលនយោបាយ អាទិភាពជាយុទ្ធសាស្ត្រ និងជាកម្មវិធីឆ្ពោះទៅរកការអភិវឌ្ឍទីក្រុងឆ្លាត ប្រកបដោយចីរភាព និងបរិយាបន្ន។ លោកក៏បានគូសបញ្ជាក់ផងដែរថា ទីភ្នាក់ងារអង្គការសហប្រជាជាតិត្រៀមខ្លួនរួចជាស្រេចនៅក្នុងការគាំ

ទ្រវាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើដំណើររួមគ្នាឆ្ពោះទៅរកការកសាងអនាគតនៃទីក្រុងឆ្លាត ប្រកបដោយចីរភាព និងបរិយាបន្ន។

### លោកស្រី Maryam Salim ប្រធានធនាគារពិភពលោកប្រចាំកម្ពុជា

លោកស្រី Maryam បានថ្លែងថា កម្ពុជាកំពុងឈរនៅចំពេលវេលាសំខាន់បំផុតនៅក្នុងដំណើរនគរូបនីយកម្មរបស់ខ្លួន ជាមួយនឹងប្រជាជនជាង ៦,១លាននាក់កំពុងរស់នៅក្នុងតំបន់ទីប្រជុំជននាពេលបច្ចុប្បន្ននេះ ហើយការផ្លាស់ប្តូរប្រជាសាស្ត្រនេះ គឺជាកម្លាំងជំរុញនៅពីក្រោយកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់កម្ពុជា។ លោកស្រីក៏បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការគ្រប់គ្រងនគរូបនីយកម្មដ៏ឆាប់រហ័សតាមរយៈការដោះស្រាយបញ្ហាបរិយាបន្ន និងការប្រែប្រួលអាកាសធាតុ ដូចជា គ្រោះទឹកជំនន់ និងការកើនឡើងសីតុណ្ហភាព។ ឧទាហរណ៍នៃភាពជាដៃគូរបស់ធនាគារពិភពលោកក្នុងការជំរុញបរិស្ថានទីក្រុងគួរឱ្យចង់រស់នៅ និងមានភាពធន់នៅកម្ពុជា គឺការអនុវត្តគំនិតផ្តួចផ្តើមស្តីពីទីក្រុងប្រកបដោយចីរភាព និងការរៀបចំ<u>របាយការណ៍កម្ពុជាស្តីពីអាកាសធាតុនិងការអភិវឌ្ឍ នៅឆ្នាំ២០២៣</u>។ លោកស្រីបានបញ្ចប់សុន្ទរកថារបស់លោកស្រីដោយសង្កត់ធ្ងន់លើវិស័យ ដែលធនាគារពិភពលោកផ្តោតការយកចិត្តទុកដាក់នៅក្នុងការផ្តល់ការគាំទ្រហិរញ្ញវត្ថុ (នោះគឺ ការពង្រឹងមូលធនមនុស្ស ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលមានភាពធន់ ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យ ព្រមជាមួយនឹងការពង្រឹងសហគមន៍) និងជំនួយបច្ចេកទេសនៅក្នុងវិស័យផ្សេងៗ (នោះគឺ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការវិភាគម៉ាក្រូសេដ្ឋកិច្ច ការវាយតម្លៃវិស័យហិរញ្ញវត្ថុ ការភ្ជាប់ទំនាក់ទំនងក្នុងតំបន់ ប្រសិទ្ធភាពថាមពល វិស័យសុខាភិបាល និងការអប់រំ ព្រមទាំងការគ្រប់គ្រងធនធានធម្មជាតិ)។

### ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

ឯកឧត្តម ខេមរ៉ូ បានសង្កត់ធ្ងន់អំពីកំណើនសេដ្ឋកិច្ចរបស់កម្ពុជានៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ បន្ទាប់ពីការរំដោះប្រទេសពីរបបប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៩។ កំណើនសេដ្ឋកិច្ចនេះបានកើតឡើងដោយផ្អែកលើការវិនិយោគដ៏ធំរបស់រដ្ឋាភិបាលក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដើម្បីទទួលបាននគរូបនីយកម្មយ៉ាងឆាប់រហ័សជាពិសេស ភាពរីកចម្រើននៃទីក្រុងទំហំមធ្យម និងទីក្រុងទំហំតូចៗ។ ឯកឧត្តមបានចែករំលែកបទពិសោធន៍អំពីគោលនយោបាយជាតិ និងកិច្ចអន្តរាគមន៍នានារបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស តួនាទី និងការរួមចំណែករបស់អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម។ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មបាននិងកំពុងរួមចំណែកចំពោះការអភិវឌ្ឍជាតិ តាមរយៈកិច្ចអន្តរាគមន៍ផ្សេងៗគ្នាពាក់ព័ន្ធនឹងកិច្ចការរៀបចំដែនដី និងនគរូបនីយកម្ម។ ឯកឧត្តមក៏បានសង្កត់ធ្ងន់លើមូលបទ និងការផ្តោតសំខាន់នៃវេទិកាជាតិលើកទី២នេះផងដែរ។ ឯកឧត្តមបានបញ្ចប់សុន្ទរកថារបស់ឯកឧត្តមដោយមានប្រសាសន៍ថា វេទិការយៈពេលមួយថ្ងៃកន្លះនេះ គឺជាវេទិកាមួយសម្រាប់កិច្ចសន្ទនារបស់ភាគីពាក់ព័ន្ធជាច្រើន ដើម្បីពិភាក្សា និងឯកភាពលើអាទិភាពគោលនយោបាយជាយុទ្ធសាស្ត្រ និងចាត់អាទិភាពលើកម្មវិធីប្រទាក់ក្រឡាគ្នា សំដៅអភិវឌ្ឍន៍នគរូបនីយកម្ម និងលំនៅឋាន ប្រកបដោយភាពឆ្លាត បៃតង មានភាពធន់ និងបរិយាបន្ន។

### ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឯកឧត្តម សាយ សំអាល់ បានបង្ហាញអំពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការដាក់ឱ្យអនុវត្ត "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១" ដែលជាការអនុវត្តគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាដើម្បីកសាង និងការពារជាតិសម្រាប់ឆ្នាំ២០២៣-២០២៨ និងបានកំណត់វិស័យអាទិភាព ៥៖ "មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា" ដែលជាក្របខណ្ឌការងាររួមសម្រាប់ដំណាក់កាលថ្មីមួយនៅក្នុងការកសាងប្រទេសកម្ពុជាឱ្យក្លាយទៅជាប្រទេសមួយដែលខ្លាំង ប្រកបដោយថាមវន្ត មានភាពរីកចម្រើន និងមានសក្តានុពលក្លាយទៅជាប្រទេសមានចំណូលខ្ពស់នៅ

វេទិកាជាតិលើកទី២ ស្តីពី
"ទីក្រុង និងលំនៅឋាន"

ត្រឹមឆ្នាំ២០៥០។ តាមរយៈការគូសបញ្ជាក់អំពីសារៈសំខាន់នៃគោលនយោបាយជាតិស្តីពីការរៀបចំដែនដី និងគោលនយោបាយជាតិស្តីពីលំនៅឋាន ឯកឧត្តមបានសង្កត់ធ្ងន់អំពីតួនាទីសំខាន់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងការរៀបចំគោលនយោបាយអាទិភាពពាក់ព័ន្ធនឹងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងលំនៅឋាន។ សមិទ្ធផលសំខាន់មួយក្នុងចំណោមសមិទ្ធផលសំខាន់ៗ គឺការរៀបចំគោលនយោបាយ "កម្ពុជា៖ មាតុភូមិខ្ញុំ"។ ឯកឧត្តមក៏បានសង្កត់ធ្ងន់ថា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងការគ្រប់គ្រង និងទំនើបកម្មនគរូបនីយកម្ម និងការអភិវឌ្ឍទីក្រុងដោយអនុលោមតាមគោលការណ៍ទីក្រុងឆ្លាតសំដៅការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការជំរុញការអភិវឌ្ឍ និងការពង្រឹងការអនុវត្តគោលនយោបាយ ច្បាប់ និងបទដ្ឋានបច្ចេកទេសដែលពាក់ព័ន្ធ។ ឯកឧត្តមបានថ្លែងពីបំណងប្រាថ្នាថា វេទិកាជាតិលើកទី២ នេះនឹងជាឱកាសល្អមួយ ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាមួយនឹងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការពង្រឹងការគ្រប់គ្រង និងទំនើបកម្មនគរូបនីយកម្ម។



"ទីក្រុងគួរឱ្យចង់រស់នៅ និងល្អសម្រាប់ប្រជាពលរដ្ឋក្នុងស្រុក និងជនបរទេសគ្រប់រូប គឺជាអ្វីដែលយើងចង់អភិវឌ្ឍ។"

**ឯកឧត្តម សាយ សំអាល់**
**ឧបនាយករដ្ឋមន្ត្រី** និងជារដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)

# វគ្គទី២៖ បទបង្ហាញដោយអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម



វគ្គទី២ បានផ្តល់ទិដ្ឋភាពរួមទូទៅស្តីពី ស្ថានបច្ចុប្បន្ននៃការរៀបចំដែនដី ក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងនគរូបនីយកម្ម និងករណីសិក្សាស្តីពីការរៀបចំប្លង់គោលនៅកម្ពុជា។

## វាគ្មិន

- **ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ** អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
- **ឯកឧត្តមបណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
- **ឯកឧត្តមបណ្ឌិត សារ៉េត បូរ៉ាមី** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

អ្នកសម្របសម្រួល៖ **ឯកឧត្តម យី យ៉ាណារតន៍** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

## សេចក្តីសង្ខេប

**ការរៀបចំដែនដីនៅកម្ពុជា៖ វឌ្ឍនភាព និងគន្លឹះឆ្ពោះទៅមុខ (គោលបំណង យន្តការ ការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ)**

*ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*

បណ្ឌិត ខេមរ៉ូ បានពន្យល់ថា នគរូបនីយកម្មយ៉ាងឆាប់រហ័សរបស់កម្ពុជាបានបង្កឡើងដោយកំណើនប្រជាជនរស់នៅតាមទីប្រជុំជន ចំណាកស្រុកពីជនបទមកទីប្រជុំជន កំណែទម្រង់រចនាសម្ព័ន្ធរដ្ឋបាលទីប្រជុំជន និងកំណែទម្រង់ចំណាត់ថ្នាក់តំបន់ទីប្រជុំជន។ ទោះបីជានគរូបនីយកម្មបានជំរុញឥទ្ធិពលវិជ្ជមានលើការអភិវឌ្ឍសេដ្ឋកិច្ចក្តី នគរូបនីយកម្មក៏មានឥទ្ធិពលអវិជ្ជមានផងដែរ។

ឧទាហរណ៍ ការអភិវឌ្ឍទីក្រុងដោយមិនមានផែនការទុកជាមុនបានបង្កឱ្យមានការប្តូរមុខងារប្រើប្រាស់ដីសម្រាប់គោលបំណងផ្សេងៗគ្នា ការខូចខាតបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ការកើនឡើងនូវការតាំងទីលំនៅមិនផ្លូវការនៅតំបន់ងាយរងគ្រោះ និងសម្ពាធលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ។ ដើម្បីឱ្យនគរូបនីយកម្មមានចីរភាព និងការរៀបចំល្អ ផែនការរៀបចំដែនដីគប្បីស្របជាមួយនឹងផែនការអភិវឌ្ឍន៍ផ្សេងទៀត ហើយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលអំពីការប្រើប្រាស់ដី និងក្របខណ្ឌច្បាប់។ ដូច្នេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានប្តេជ្ញាចិត្តក្នុងការគ្រប់គ្រង និងត្រួតពិនិត្យធនធានដី ដើម្បីសម្របសម្រួលលទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានដី និងការរៀបចំដែនដីនៅក្នុងបរិបទនៃសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ ការផ្តល់លំនៅឋាន និងកំណើនសេដ្ឋកិច្ច។

**ក្របខណ្ឌច្បាប់ និងគតិយុត្តស្តីពីការរៀបចំទីក្រុង និងនគរូបនីយកម្ម**

វេទិកាជាតិលើកទី២ ស្តីពី

"ទីក្រុង និងលំនៅឋាន"

*ឯកឧត្តមបណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*

ឯកឧត្តមបណ្ឌិត ប៊ុណ្ណារិទ្ធ បានចាប់ផ្តើមបទបង្ហាញតាមរយៈការគូសបញ្ជាក់អំពីសារៈសំខាន់នៃក្របខណ្ឌច្បាប់ និងគតិយុត្តដែលពាក់ព័ន្ធ នៅក្នុងការអភិវឌ្ឍនគរូបនីយកម្ម និងការធានាឱ្យបាននូវទីក្រុងដែលមានសុវត្ថិភាព និង មានលំហ ឬឧទ្យានសាធារណៈ បៃតង និងអនាម័យប្រកបដោយបរិយាបន្ន។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានយន្តការរៀបចំ និងអនុវត្តផែនការរៀបចំដែនដី និងនគរូបនីយកម្ម នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះជាយ៉ាងណាក្តី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក៏ទទួលស្គាល់បញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តផងដែរ ដូចជាសមត្ថភាពក្នុងការរៀបចំឬអនុវត្តផែនការនៅមានកម្រិត ឧបករណ៍រៀបចំឬគ្រប់គ្រងមិនទាន់គ្រប់ជ្រុងជ្រោយ ព្រមទាំងការចូលរួម និងការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធនៅមានកម្រិត។

**ករណីសិក្សាស្តីពីការរៀបចំប្លង់គោលប្រើប្រាស់ដីស្រុកសេសាន ខេត្តស្ទឹងត្រែង និងសង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត**

*ឯកឧត្តមបណ្ឌិត សារ៉េត បូរ៉ាមី អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*

ឯកឧត្តមបណ្ឌិត បូរ៉ាមី បានបង្ហាញករណីសិក្សាអំពីផែនការរៀបចំដែនដីខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣០ ដើម្បីរៀបចំតំបន់សេដ្ឋកិច្ចសមុទ្រ តាមរយៈការគ្រប់គ្រងការប្រើប្រាស់ដី ធនធានធម្មជាតិ និងនគរូបនីយកម្មប្រកបដោយចីរភាព ធន់ និងបរិយាបន្ន។ ទិសដៅមួយទៀតនៃផែនការរៀបចំដែនដីនេះ គឺដើម្បីជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច រួមទាំងការអភិរក្សបរិស្ថាន និងវប្បធម៌ ព្រមទាំងការទប់ស្កាត់គ្រោះមហន្តរាយធម្មជាតិ។

ឯកឧត្តមក៏បានបង្ហាញករណីសិក្សាមួយទៀតពីស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលបានរៀបចំប្លង់គោលប្រើប្រាស់ដីមួយ រួមទាំងផែនការប្រើប្រាស់ដី សម្រាប់ការអភិវឌ្ឍស្រុកនេះនៅពេលអនាគត។ ដូច្នេះ ប្លង់គោលនេះមានផែនការសម្រាប់ការប្រើប្រាស់ដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ច។ ប្លង់គោលនៅស្រុកសេសានអាចជាទិន្នន័យដើមគ្រា សម្រាប់ការធ្វើសេចក្តីសម្រេចនៅពេលអនាគត។ ផែនការប្រើប្រាស់ដីសង្កាត់អណ្តូងខ្មែរនៅខេត្តកំពត ក៏ជាឧទាហរណ៍មួយទៀតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីក្រុង ស្រុក ខណ្ឌ តាមរយៈការចងក្រងការរៀបចំដែនដី និងការប្រមូលទិន្នន័យថ្នាក់ភូមិ។ កិច្ចប្រជុំជាច្រើនបានរៀបចំ ដើម្បីប្រមូលទិន្នន័យ និងកំណត់ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍសង្កាត់ និងការរៀបចំផែនការប្រើប្រាស់ដី។





# វគ្គទី៣៖ បទបង្ហាញដោយដៃគូអភិវឌ្ឍន៍ និងកិច្ចពិភាក្សា



វគ្គទី៣ គឺជាវគ្គដែលដៃគូអភិវឌ្ឍន៍ចែករំលែកបទពិសោធន៍ និងរបកគំហើញពាក់ព័ន្ធនឹងនគរូបនីយកម្មនៅកម្ពុជា ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព និងឆ្លាត ដំណោះស្រាយផ្អែកលើធម្មជាតិ និងការរៀបចំដែនដី។

## វាគ្មិន

- **លោក** Andre A. Bald ប្រធានក្រុមអ្នកឯកទេសផ្នែកទីក្រុងនៃធនាគារពិភពលោក
- **លោកស្រី** Jessica Schmidt អ្នកឯកទេសផ្នែកទីក្រុងនៃធនាគារពិភពលោក
- **លោក** Stamatis Kotouzas អ្នកឯកទេសជាន់ខ្ពស់ផ្នែករដ្ឋបាលដីធ្លីនៃធនាគារពិភពលោក

  **លោក សុខ វណ្ណា និងលោក** Sangmin Nam តំណាងឱ្យទីភ្នាក់ងារអង្គការសហប្រជាជាតិ (UNESCAP, UN-Habitat, UNOPS)
- **លោក** Jun Fujihira មន្ត្រីកម្មវិធីនៃអង្គការ UN-Habitat ប្រចាំកម្ពុជា
- **លោក** Alvin Lopez អ្នកឯកទេសជាន់ខ្ពស់ផ្នែកធនធានធម្មជាតិ និងកសិកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី

អ្នកសម្របសម្រួល៖ **ឯកឧត្តម ម៉េង ប៊ុណ្ណារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

## សេចក្តីសង្ខេប

### ទីក្រុងគួរឱ្យចង់រស់នៅសម្រាប់អនាគតកម្ពុជា

*លោក Andre A. Bald ប្រធានក្រុមអ្នកឯកទេសផ្នែកទីក្រុងនៃធនាគារពិភពលោក*

កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលដំបូងនៃបរិវត្តកម្មដែនដីរបស់ខ្លួន ដែលស្របជាមួយនឹងកំណើនប្រជាជនរស់នៅក្នុងទីប្រជុំជនយ៉ាងឆាប់រហ័ស។ នៅឆ្នាំ២០០៨ ប្រជាជនរស់នៅតាមទីប្រជុំជនមានចំនួន២៧,៧% ប៉ុន្តែតួលេខនេះបានកើនឡើងដល់៣៩,១% នៅឆ្នាំ២០១៨។ នគរូបនីយកម្មបានជួយកាត់បន្ថយភាពក្រីក្រ និងបង្កឱកាសការងារកាន់តែល្អប្រសើរនៅកម្ពុជា។ ទោះជាយ៉ាងណាក្តី មានសេចក្តីរាយការណ៍ថា កត្តាជំរុញវឌ្ឍនភាពសេដ្ឋកិច្ចរបស់កម្ពុជាដែលមានពីមុន (ផលិតកម្ម និងកសិកម្មដែលប្រើប្រាស់កម្លាំងពលកម្ម និងមានជំនាញទាប) មិនគ្រប់គ្រាន់ដើម្បីសម្រេចឱ្យបានគោលដៅជាប្រទេសមានចំណូលមធ្យមខ្ពស់នៅត្រឹមឆ្នាំ២០៣០ឡើយ។ កត្តាជំរុញសំខាន់ៗចំពោះភាពរីកចម្រើន និងការកាត់បន្ថយភាពក្រីក្រនាពេលអនាគត (ផលិតកម្ម ទេសចរណ៍ ពាណិជ្ជកម្ម និងសេវាកម្ម) ភាគច្រើនស្ថិតនៅតាមទីប្រជុំជន។ ដោយសារនគរូបនី

យកម្មយ៉ាងឆាប់រហ័ស ធនធាននៅមានកម្រិត និងភាពងាយរងគ្រោះកម្រិតខ្ពស់ចំពោះការប្រែប្រួលអាកាសធាតុ ការព្យាករណ៍មួយបង្ហាញថា កម្ពុជានឹងប្រឈមមុខជាមួយនឹងបញ្ហានគរូបនីយកម្មមួយចំនួនដូចជា គ្រោះមហន្តរាយធម្មជាតិ និងការបញ្ចេញកាបូននៅក្នុងបរិយាកាស។ ជាអនុសាសន៍ កម្ពុជាគប្បីអភិវឌ្ឍទីក្រុងបញ្ចេញកាបូនទាបដែលមានប្រសិទ្ធភាព និងតម្លៃទាបជាង ហើយប្រជាពលរដ្ឋាចទទួលបានគុណភាពជីវិតមួយដែលកាន់តែល្អ។



**“នគរូបនីយកម្មបានជួយកាត់បន្ថយភាពក្រីក្រ និងបានបង្កើតឱកាសការងារកាន់តែល្អនៅកម្ពុជា។”**

*លោក Andre A. Bald ប្រធានក្រុមអ្នកឯកទេសផ្នែកទីក្រុងនៃធនាគារពិភពលោក*

## របកគំហើញសំខាន់ៗពីគំនិតផ្តួចផ្តើមទីក្រុងប្រកបដោយចីរភាពនៅកម្ពុជា៖ អន្តរកាលឆ្ពោះទៅរកការបញ្ចេញកាបូនទាប និងមធ្យោបាយធន់នឹងអាកាសធាតុ

*លោកស្រី Jessica Schmidt អ្នកឯកទេសផ្នែកទីក្រុងនៃធនាគារពិភពលោក*

ដោយសារនគរូបនីយកម្ម និងកំណើនប្រជាជនយ៉ាងឆាប់រហ័សនៅកម្ពុជា តម្រូវការទឹក អនាម័យ និងអគ្គិសនីបានកើនឡើងយ៉ាងខ្លាំងនៅក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ ឯកសារបោះពុម្ពផ្សាយ និងការវិភាគផ្សេងៗរបស់ធនាគារពិភពលោកបានផ្តល់ការពន្យល់អំពី ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចសង្គមនៃការប្រែប្រួលអាកាសធាតុ ឥទ្ធិពលនៃកំណើនរលកកម្ដៅនៅតំបន់ទីក្រុង និងភាពរីកចម្រើនពាក់ព័ន្ធនឹងការរៀបចំដែនដីនៅរាជធានីភ្នំពេញ ត្រូវបានបរិយាយ។ ការវាយតម្លៃគំនិតផ្តួចផ្តើមទីក្រុងប្រកបដោយចីរភាពនៅកម្ពុជា បានកំណត់មធ្យោបាយជាយុទ្ធសាស្ត្រសំខាន់ៗសម្រាប់រាជធានីភ្នំពេញ រួមមាន (១) ការសម្រេចបានវិស័យថាមពលកាន់តែស្អាត (២) ការរៀបចំផែនការនគរូបនីយកម្មដែលធន់នឹងអាកាសធាតុ និងបញ្ចេញកាបូនទាប (៣)ការជំរុញការធ្វើដំណើរដែលសកម្ម និង (៤)ការកែសម្រួលការអនុវត្តការគ្រប់គ្រងទឹក និងសំណល់ប្រកបដោយចីរភាព។ ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុរបស់ទីក្រុងទំហំមធ្យម ធនាគារពិភពលោកក៏បានបង្ហាញអំពីសារៈសំខាន់នៃ (១) ការគាំទ្រយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលចំពោះប៉ូល និងរបៀងកំណើនសេដ្ឋកិច្ច (២) ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុ និងហានិភ័យនៃគ្រោះមហន្តរាយ ព្រមទាំងបរិយាបន្នសង្គមទៅក្នុងការរៀបចំផែនការថ្នាក់មូលដ្ឋាន និងថ្នាក់រាជធានី ខេត្ត និង (៣) ការផ្តល់ការយល់ដឹងកាន់ជាក់ច្បាស់អំពី ហិរញ្ញប្បទានទីក្រុង ដើម្បីគាំទ្រយុទ្ធសាស្ត្របន្សាំនឹងអាកាសធាតុ។

## ការវាយតម្លៃដីធ្លី និងអចលទ្រព្យសម្រាប់ការប្រមូលពន្ធនៅតំបន់អាស៊ាន

*លោក Stamatis Kotouzas អ្នកឯកទេសជាន់ខ្ពស់ផ្នែករដ្ឋបាលដីធ្លីនៃធនាគារពិភពលោក*

របាយការណ៍ដែលគ្របដណ្តប់លើប្រទេសអាស៊ានចំនួន ៧ បានរកឃើញថា រដ្ឋបាលដីធ្លី គឺជាមូលដ្ឋានគ្រឹះសម្រាប់ការវាយតម្លៃ និងការប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព ប៉ុន្តែប្រព័ន្ធរដ្ឋបាលដីធ្លីនៅតែមានភាពរាយប៉ាយទាក់ទងនឹងការគ្របដណ្តប់ និងការចែករំលែកទិន្នន័យ។ ទោះជាពន្ធលើអចលនទ្រព្យអាចត្រូវប្រមូលតាមរយៈវិធីខុសៗគ្នា ដូចជាការប្រមូលពន្ធប្រចាំឆ្នាំលើអចលទ្រព្យ និងពន្ធនៃការផ្ទេរអចលនទ្រព្យក្តី មានសក្តានុពលមួយដែលគេមិនទាន់បានយកមកប្រើប្រាស់ ដោយសារការប្រកាសអំពីតម្លៃមិនបានគ្រប់ចំនួន ការវាយតម្លៃដែលហួសសុពលភាព កង្វះតម្លាភាព ការអនុវត្តច្បាប់នៅទន់ខ្សោយ និងតម្រូវការក្នុងការលើកទឹកចិត្តការអនុលោមតាមច្បាប់។ បញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមនានា គឺការទទួលបានទិន្នន័យសម្រាប់ការវាយតម្លៃ ដោយសារគ្មានការប្រមូលផ្តុំទិន្នន័យនៅក្នុងមូលដ្ឋានទិន្នន័យ។ ដើម្បីឱ្យការវាយតម្លៃដីធ្លី និងអចលនទ្រព្យនៅកម្ពុជាបានត្រឹមត្រូវ កម្ពុជាគប្បីបង្កើត

វេទិកាជាតិលើកទី២ ស្តីពី
"ទីក្រុង និងលំនៅឋាន"
ប្រព័ន្ធប្រតិបត្តិការអចលនទ្រព្យដែលប្រើប្រាស់ទិន្នន័យ និងបច្ចេកវិទ្យាព័ត៌មាន ការវាយតម្លៃទ្រង់ទ្រាយធំ និងការកសាងសមត្ថភាព។

**របកគំហើញសំខាន់ៗពីរបាយការណ៍វាយតម្លៃទីក្រុងឆ្លាតផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតថ្នាក់ជាតិ ការបង្កើតយុទ្ធសាស្ត្រទីក្រុងឆ្លាតថ្នាក់ជាតិ និងសំណើយុទ្ធសាស្ត្រទីក្រុងឆ្លាតសម្រាប់ខេត្តព្រះសីហនុ**

*លោក សុខ វណ្ណា ប្រធានកម្មវិធីនៃអង្គការ UN-Habitat ប្រចាំកម្ពុជា និងលោក Sangmin Nam មកពី UNESCAP តំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ (UNESCAP UN-Habitat និង UNOPS)*

UNOPS និង UN-Habitat បាននិងកំពុងអនុវត្តគម្រោង "ទីក្រុងសម្រាប់ទាំងអស់គ្នា៖ការអភិវឌ្ឍទីក្រុងប្រកបដោយបរិយាបន្ន ឆ្លាត និងចីរភាពនៅកម្ពុជា" ចាប់ពីឆ្នាំ២០២៣ មក។ គម្រោងនេះបានរៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវទីក្រុងឆ្លាត ដោយផ្អែកលើការវាយតម្លៃទីក្រុងឆ្លាតនៅទីក្រុងចំនួនបួននៃប្រទេសកម្ពុជា។ របកគំហើញនៃការវាយតម្លៃនេះបង្ហាញឱ្យឃើញថា ការអភិវឌ្ឍទីក្រុងឆ្លាតនឹងជាឱកាសមួយក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថលដើម្បីពង្រឹង និងសម្របសម្រួលការអភិវឌ្ឍទីក្រុង និងផ្តល់ឱកាសសម្រាប់ពលរដ្ឋចូលរួម។ របកគំហើញនេះក៏បានបញ្ជាក់ថា អភិក្រមទីក្រុងឆ្លាតនឹងធានាដំណើរការនៃការផ្តល់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ និងសេវាជាមូលដ្ឋានជូនដល់ប្រជាជនគ្រប់រូបតាមរយៈការជំរុញទំនាក់ទំនងរវាងពលរដ្ឋ និងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការវាយតម្លៃនេះក៏បានបង្ហាញអំពីបញ្ហាប្រឈមរបស់សហគមន៍ងាយរងគ្រោះ និងបានឯកភាពចំពោះទទួលបានផលប្រយោជន៍ប្រកបដោយបរិយាបន្នជូនពលរដ្ឋទាំងអស់ ដោយមិនទុកនរណាម្នាក់ចោលទេ។ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃបានរៀបចំផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតជាតិកម្ពុជា ២០២៣-២០៣៥ ដោយសហការជាមួយអង្គការ UNOPS និង UN-Habitat ។ UNESCAP និង UN-Habitat ក៏បានគាំទ្រក្រសួងមហាផ្ទៃនៅក្នុងការរៀបចំយុទ្ធសាស្ត្រទីក្រុងឆ្លាតជាតិ (NSCS) ផងដែរ ដើម្បីពង្រឹងសេវាកម្ម និងគុណភាពជីវិតនៅតាមទីប្រជុំជននៅកម្ពុជា និងស្របពេលជាមួយគ្នានោះក៏ជំរុញកំណើនសេដ្ឋកិច្ច និងចីរភាពបរិស្ថាន ព្រមទាំងធានាថា ប្រជាជនដែលមិនសូវទទួលបានការយកចិត្តទុកដាក់ និងប្រជាជនដែលងាយរងគ្រោះនឹងមិនត្រូវបានទុកចោលផងដែរ។ NSCSចុងក្រោយត្រូវបានរំពឹងថានឹងទទួលបានការអនុម័តពីរដ្ឋាភិបាលនៅត្រឹម ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤។




"ការអភិវឌ្ឍទីក្រុងឆ្លាតនឹងជាឱកាសមួយក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថលដើម្បីធ្វើឱ្យប្រសើរឡើង និងសម្របសម្រួលការអភិវឌ្ឍទីក្រុង។"

*លោក សុខ វណ្ណា ប្រធានកម្មវិធី នៃអង្គការ UN-Habitat ប្រចាំកម្ពុជា*

**ការចែករំលែកបទពិសោធន៍ និងគំនិតសក្តានុពលនៃដំណោះស្រាយផ្អែកលើធម្មជាតិសម្រាប់តំបន់លំនៅឋានបណ្តោះអាសន្ន**

*លោក Jun Fujihira មន្ត្រីកម្មវិធីនៃអង្គការ UN-Habitat ប្រចាំកម្ពុជា*

ដំណោះស្រាយផ្អែកលើធម្មជាតិ (NBS) គឺជា "វិធានការដែលជំរុញទំនាក់ទំនងរវាងជីវចម្រុះ និងសុខុមាលភាពរបស់មនុស្សក្នុងលក្ខខណ្ឌដែលទាំងជីវចម្រុះ និងសុខុមាលភាពរបស់មនុស្សឆ្លើយតបនឹងគុណតម្លៃ និងបញ្ហាប្រឈមផ្នែកសង្គម និងវប្បធម៌ ព្រមទាំងការពារ និងពង្រឹងប្រព័ន្ធអេកូឡូស៊ីសម្រាប់បន្តការផ្តល់សេវាកម្មនានា។" ដំណោះស្រាយបែបនេះ គឺជាកិច្ចអន្តរាគមន៍មួយនៃកិច្ចអន្តរាគមន៍ប្រកបដោយសក្តានុពលនានាក្នុងការដោះស្រាយបញ្ហា

ប្រឈមរបស់សង្គមតាមរយៈការប្រើប្រាស់ដំណើរការប្រព័ន្ធអេកូឡូស៊ី។ អង្គការ UN-Habitat មានបទពិសោធន៍ជាសកលក្នុងការអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិនៅក្នុងប្រទេសជាច្រើន ដូចជាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ រួមមានប្រទេសនេប៉ាល់ មីយ៉ាន់ម៉ា ម៉ុងហ្គោលី និងហ្វីលីពីន។ ដំណោះស្រាយផ្អែកលើធម្មជាតិប្រកបដោយសក្តានុពលមួយចំនួន មានទិសដៅស្របទៅនឹងគោលនយោបាយជាតិ និងផែនការសកម្មភាពរបស់កម្ពុជា និងអាចអនុវត្តបានចំពោះកម្ពុជាផងដែរ។ ទោះបីជាយ៉ាងណាក្តី ដំណោះស្រាយផ្អែកលើធម្មជាតិគប្បីត្រូវរៀបចំ និងអនុវត្តដោយផ្អែកលើការវិភាគបរិបទជាក់លាក់ និងមានការចូលរួម ដើម្បីបញ្ចៀសលទ្ធផលដែលមិនឆ្លើយតបទៅតាមស្ថានភាពជាក់ស្តែង ឬគោលបំណងដែលគ្រោងទុកនៅក្នុងតំបន់គោលដៅ។

### ផែនការរៀបចំដែនដី៖ ជំរុញសមាហរណកម្មអន្តរវិស័យសម្រាប់ការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព

*លោក Alvin Lopez អ្នកឯកទេសជាន់ខ្ពស់ផ្នែកធនធានធម្មជាតិ និងកសិកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី*

ផែនការយុទ្ធសាស្ត្ររៀបចំដែនដីមានសារៈសំខាន់ ដោយសារផែនការនេះនឹងត្រូវរៀបចំឡើងតាមរយៈមូលដ្ឋានគ្រឹះនៃការរៀបចំដែនដី ដូចជាការប្រើប្រាស់ដី ខណៈធ្វើឱ្យគុណភាពជីវិតប្រសើរឡើង ព្រមទាំងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាពផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ីបាននិងកំពុងចាប់ដៃគូ ជាមួយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអភិវឌ្ឍនគរូបនីយកម្ម ការរៀបចំដែនដី ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រជំរុញកំណើនសេដ្ឋកិច្ច។ អនុសាសន៍មួយចំនួនបានលើកឡើង រួមមាន (១) ការបង្កើតវេទិកា និងយន្តការចែករំលែក ឬផ្តោះប្តូរទិន្នន័យភូមិសាស្ត្រនៅទូទាំងប្រទេស (២) ការបន្សុីការប្រើប្រាស់ដីទៅនឹងការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីពង្រឹងលទ្ធផលផ្នែកសេដ្ឋកិច្ច និងបរិស្ថាន និង (៣) ការវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ចកាន់តែទូលំទូលាយតាមរយៈការភ្ជាប់ទំនាក់ទំនងរវាងលទ្ធផលនៃការរៀបចំផែនការ និងអាទិភាពនៃការវិនិយោគ ជាមួយនឹងការវាយតម្លៃសេដ្ឋកិច្ចតាមតំបន់ឬតាមទីតាំង ដែលប៉ាន់ស្មានអំពីផលប្រយោជន៍ដោយប្រយោលចំពោះសេដ្ឋកិច្ចទូទៅ ដូចជា ប្រាក់ចំណូលកំណើនសេដ្ឋកិច្ច និងការងារ។

ADB នឹងផ្តល់ជំនួយបច្ចេកទេសលើការរៀបចំផែនការយុទ្ធសាស្ត្រជាតិរៀបចំដែនដី ដើម្បីរួមចំណែកចំពោះការពង្រឹងប្រសិទ្ធភាពនៃការវិនិយោគលើសេដ្ឋកិច្ចទាំងនៅក្នុងព្រំដែនរាជធានី ខេត្ត និងប៉ូលឬរបៀងសេដ្ឋកិច្ច តាមរយៈការបង្កើនភាពច្បាស់លាស់នៃផែនការរៀបចំដែនដីនៃធនធានធម្មជាតិ ការកសាងបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធលីនីអ៊ែរនៅកម្ពុជា។ តាមរយៈជំនួយបច្ចេកទេសនេះ ជាដំបូង គម្រោងនឹងរៀបចំបង្កើតនីតិវិធីរៀបចំផែនការយុទ្ធសាស្ត្រជាតិ ការគាំទ្រចំពោះសេចក្តីសម្រេចឌីជីថល និងសមត្ថភាពរៀបចំដែនដី។ បន្ទាប់មកទៀត គម្រោងនឹងអនុវត្តសាកល្បងនៅតាមតំបន់នៃរាជធានី ខេត្តមួយចំនួន ដើម្បីផ្តល់ជាភស្តុតាងចំពោះការរៀបចំបញ្ចប់ NSSP SOP និងកម្មវិធីសម្រាប់ការអនុវត្តនៅទូទាំងកម្ពុជា។







# ៣. សេចក្តីសង្ខេបវគ្គនិមួយៗ (ថ្ងៃទី២)

## វគ្គទី៤៖ ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យនៅកម្ពុជា



វគ្គទី៤ បានឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យនៅតំបន់ទីប្រជុំជន ការអនុវត្តល្អៗជាសកល និងមេរៀនដែលទទួលបាន ព្រមទាំងឧទាហរណ៍អំពីភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យនៅកម្ពុជា។

### វាគ្មិន

- **លោក សុខ សំអូន** អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាន
- **លោកស្រី** Dao Harrison អ្នកឯកទេសជាន់ខ្ពស់ផ្នែកលំនៅឋាននៃធនាគារពិភពលោក
- **លោក យក់ សុធីរិទ្ធ** នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន WorldBridge Homes Co., Ltd.

អ្នកសម្របសម្រួល៖ **ឯកឧត្តម ឈឹម សុគន្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

### សេចក្តីសង្ខេប

**ស្ថានភាពលំនៅឋានតម្លៃសមរម្យក្នុងទីក្រុងនៅកម្ពុជា**

*លោក សុខ សំអូន អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាន*

នគរូបនីយកម្មឆាប់រហ័សនៅក្នុងប្រទេសជាកត្តារារាំងគ្រួសារដែលមានចំណូលទាប និងមធ្យមពីការទិញលំនៅឋានផ្ទាល់ខ្លួន ដោយសារតែតម្លៃខ្ពស់។ ដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយផ្សេងៗគឺការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ដែលមានតម្លៃទាប ការរចនា និងការប្រើប្រាស់សម្ភារៈដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន។

គោលនយោបាយជាតិស្តីពីលំនៅឋានតម្លៃសមរម្យមានគោលដៅ និងយុទ្ធសាស្ត្រ ដើម្បីធានាថា គ្រួសារកម្ពុជាទាំងអស់មានលំនៅឋានសមរម្យ ប្រកបដោយផាសុកភាព និងសុវត្ថិភាព ក្រោមកិច្ចសហការជាមួយវិស័យសាធារណៈ និងឯកជន។ លំនៅឋានតម្លៃសមរម្យគប្បីមានការរចនាប្រកបដោយផាសុកភាពជាមួយនឹងរចនាសម្ព័ន្ធដែលមានភាពធន់ និងមានតម្លៃសមរម្យសម្រាប់គ្រួសារងាយរងគ្រោះ។ គំរូលំនៅឋានមានតម្លៃសមរម្យមួយចំនួនត្រូវបានបង្ហាញក្នុងវេទិកាជាតិលើកទី២នេះ។ បទបង្ហាញបានធ្វើសេចក្តីសន្និដ្ឋានជាមួយនឹងការប្តេជ្ញាចិត្តក្នុងការឆ្លើយតប

វេទិកាជាតិលើកទី២ ស្តីពី
“ទីក្រុង និងលំនៅឋាន”

នឹងនគរូបនីយកម្មឆាប់រហ័ស នៅកម្ពុជាតាមរយៈការសាងសង់លំនៅឋានតម្លៃសមរម្យ ដោយមានកិច្ចសហការរវាងអគ្គនាយកដ្ឋានលំនៅឋាន និងវិស័យឯកជន។



## “លំនៅឋានមានតម្លៃសមរម្យ គឺជាដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយសក្តានុពលនានា ដើម្បីផ្តល់លំនៅឋានដល់ប្រជាពលរដ្ឋគ្រប់រូប។”

*លោក សុខ សំអូន អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាន*

**វិស័យលំនៅឋាននៅកម្ពុជា៖ ទិដ្ឋភាពទូទៅនៃទីផ្សារលំនៅឋាន និង បទពិសោធន៍ល្អៗក្នុងតំបន់**

*លោកស្រី Dao Harrison អ្នកឯកទេសជាន់ខ្ពស់ផ្នែកលំនៅឋាននៃធនាគារពិភពលោក*

នៅកម្ពុជា ប្រជាជនចំនួន ៣៩,៧% រស់នៅក្នុងតំបន់សំណង់បណ្តោះអាសន្ន ហើយតម្រូវការលំនៅឋានក្នុងទីក្រុងពីឆ្នាំ២០១៥ ទៅ ២០២៣មានចំនួន ៧៧៧.២៧៣ខ្នង។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាមានទិសដៅសាងសង់លំនៅឋានតម្លៃសមរម្យ ១លានខ្នងនៅត្រឹមឆ្នាំ២០៣០។ ដូចដែលមានចែងក្នុងគោលនយោបាយស្តីពីការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យអនុម័តឆ្នាំ២០១៧ ចំណុចមួយចំនួនគប្បីត្រូវបានដោះស្រាយដើម្បីជំរុញការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ៖ (១) លទ្ធភាពទទួលបានដី និងការរៀបចំផែនការកាន់តែល្អ (២) ការពង្រឹងគុណភាព និងភាពធន់របស់សំណង់លំនៅឋាន តាមរយៈការប្រើប្រាស់កូដសម្រាប់ការសាងសង់ និងការផ្តល់វិញ្ញាបនបត្របៃតង និង (៣)ការធ្វើឱ្យតម្លៃកាន់តែ សមរម្យ។ ធនាគារពិភពលោកបានគាំទ្រប្រទេសឥណ្ឌូនេស៊ីនៅក្នុងការធ្វើឱ្យប្រសើរឡើងការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ តាមរយៈការផ្តល់ការឧបត្ថម្ភធនសម្រាប់កម្ចីទិញលំនៅឋាន និងប្រទេសម៉ាល់ឌីវតាមរយៈការរៀបចំសៀវភៅណែនាំដែលមានលក្ខណៈសាមញ្ញស្តីពីលំនៅឋានដែលមានភាពធន់ សម្រាប់ម្ចាស់លំនៅឋានអាចធ្វើការសាងសង់ ឬជួសជុលដោយខ្លួនឯង។ សៀវភៅណែនាំនេះបានគូសបញ្ជាក់ថា ម្ចាស់លំនៅឋានគប្បីផ្តោតការយកចិត្តទុកដាក់លើមិនត្រឹមតែតម្លៃសមរម្យប៉ុណ្ណោះឡើយ ប៉ុន្តែថែមទាំងភាពធន់ចំពោះគ្រោះមហន្តរាយ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុផងដែរ។ តុល្យភាពល្អនៃការវិនិយោគឬការចូលរួមរបស់វិស័យសាធារណៈ និងឯកជនមានភាពចាំបាច់ក្នុងការជំរុញកំណើនទីផ្សារលំនៅឋាន និង ប្រសិទ្ធភាពចំណាយ ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងមិនបង្កផលប៉ះពាល់ដល់បរិស្ថាន។



## “ការដាក់បញ្ចូលភាពធន់នឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុពិតជាមានសារៈសំខាន់។”

*លោកស្រី Dao Harrison អ្នកឯកទេសជាន់ខ្ពស់ផ្នែកលំនៅឋាននៃធនាគារពិភពលោក*

**គម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ “ទីក្រុងរណបសិរីមង្គល”**

*លោក យក់ សុធីរិទ្ធ នាយកគ្រប់គ្រងនៃក្រុមហ៊ុន WorldBridge Homes Co., Ltd.*

ក្រុមហ៊ុន World Bridge Homes គឺជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន World Bridge Group ដែលបង្កើតឡើងនៅឆ្នាំ ២០១៧ ក្នុងនាមជាក្រុមហ៊ុនអភិវឌ្ឍអចលនទ្រព្យនាំមុខ ជាមួយនឹងបេសកកម្មផ្តល់លំនៅឋានតម្លៃសមរម្យដែល មានគុណភាពស្តង់ដាកម្រិតខ្ពស់ ប្រកបដោយផាសុកភាព និងសុវត្ថិភាពបរិស្ថាន សម្រាប់គ្រួសារកម្ពុជា ដែលស្ថិតក្នុងចំណោមគ្រួសារដែលមានចំណូលទាបទៅមធ្យម។ បន្ថែមលើតម្លៃ ក្រុមហ៊ុន World Bridge Homes ក៏យកចិត្តទុកដាក់លើគុណភាពសំណង់ និងសម្ភារៈ ការរចនាប្រកបដោយចីរភាព និងមិនប៉ះពាល់ដល់បរិស្ថាន ការបង្កើតតំបន់ពាណិជ្ជកម្ម និងទីផ្សារ តាមរយៈការពិចារណាលើសកម្មភាពសេដ្ឋកិច្ច ទីធ្លាសាធារណៈ និងលំហបៃតង សុវត្ថិភាព និងភាពងាយស្រួលក្នុងការទទួលបានសេវាកម្មដឹកជញ្ជូនសាធារណៈ។ ដោយសារតែមានការគិតគូរលើចំណុចទាំងនេះ គម្រោងលំនៅឋានតម្លៃសមរម្យរបស់ក្រុមហ៊ុនបានក្លាយទៅជាគម្រោងគំរូ ស្របពេលដែលក្រុមហ៊ុនបានទទួលពានរង្វាន់ធុរកិច្ចប្រកបដោយបរិយាបន្នពីរាជរដ្ឋាភិបាលកម្ពុជា។ គម្រោងនេះ គឺជាគំរូដ៏ល្អនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន។



វេទិកាជាតិលើកទី២ ស្តីពី
"ទីក្រុង និងលំនៅឋាន"












# វគ្គទី៥៖ បទបង្ហាញដោយបេក្ខជនជ័យលាភីនៃកម្មវិធីប្រឡងប្រណាំងស្នាដៃសិក្សារចនាទីក្រុង




នៅក្នុងវគ្គទី៥ បេក្ខជនតំណាងក្រុមជ័យលាភីនិមួយៗនៃកម្មវិធីប្រឡងប្រណាំងស្នាដៃសិក្សារចនាទីក្រុងដែលរៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានធ្វើបទបង្ហាញពីគម្រោងរចនាដែលក្រុមបានរៀបចំឡើង ។ ការប្រឡងប្រណាំងនេះមានគោលបំណងសំខាន់ៗដូចជា៖ (១) ជំរុញការអភិវឌ្ឍទីប្រជុំជនដោយការរចនាប្រកបសោភ័ណភាព រៀបរយ និងមិនបង្កផលប៉ះពាល់ដល់បរិស្ថាន (២) ការកែលម្អសេវាកម្មទីក្រុងសម្រាប់ពលរដ្ឋទាំងអស់ និង (៣) ការអភិរក្ស ឬការលើកកម្ពស់បេតិកភណ្ឌប្រវត្តិសាស្ត្រ និងវប្បធម៌។

ក្រុមចំនួន ៣០ បានដាក់ស្នើគំនិតរចនារបស់ខ្លួន ដោយផ្តោតលើតំបន់ខាងក្រោម៖

១. មហាវិថីព្រះនរោត្តមពីវិមានឯករាជ្យ (ផ្លូវលេខ ៤១) ឆ្ពោះទៅរមណីយដ្ឋានវត្តភ្នំ
២. មហាវិថីព្រះមុនីវង្សពីស្តុបទេព្យចិន (ផ្លូវលេខ ៩៣) ឆ្ពោះទៅស្ពានចាស់
៣. សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងតំបន់ជុំវិញ
៤. សារមន្ទីរប្រល័យពូជសាសន៍ជើងឯក និងតំបន់ជុំវិញ

## វាគ្មិន

- **លោក អ៊ួន ឧត្តម** អ្នកតំណាងក្រុមមកពីអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
- **លោក តែ ម៉េឡូឌី** អ្នកតំណាងស្ថាបត្យករមកពីក្រុមហ៊ុនបូរី ML
- **លោក ចន្ទី ម៉ានីវ័ត្ន** អ្នកតំណាងស្ថាបត្យករមកពីក្រុមហ៊ុន Group Four Architects & Engineers
- **លោក នូរ មុនីរ័តន៍** អ្នកតំណាងស្ថាបត្យករមកពីក្រុមហ៊ុន AO Architects Design & Engineering Co., LTD
- **លោក គួ កែវវិបុល** អ្នកតំណាងស្ថាបត្យករមកពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

អ្នកសម្របសម្រួល៖ **ឯកឧត្តម សេក សុធីរិទ្ធ** ប្រធាននាយកដ្ឋាននគរូបនីយកម្ម

## សេចក្តីសង្ខេប

**ផ្លូវ៣០៦ ខណ្ឌសែនសុខ គម្រោងកែលម្អប្រឡាយទឹក មហាវិថីព្រះនរោត្តម ពីវិមានឯករាជ្យ (ផ្លូវលេខ ៤១) ឆ្ពោះទៅរមណីយដ្ឋានវត្តភ្នំ**

*លោក អ៊ួន ឧត្តម អ្នកតំណាងក្រុមមកពីអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*

នៅតាមបណ្តោយផ្លូវលេខ ៣០៧ ខណ្ឌសែនសុខ មានបឹងមួយឈ្មោះថាបឹងពោងពាយ ដែលឈ្មោះនេះមានជាយូរមកហើយតាំងពីមុនពេលមាននគរូបនីយកម្មនៅជុំវិញតំបន់នោះ។ នគរូបនីយកម្មបានជំរុញឱ្យមានការចាក់ដីលុបនៅផ្នែកខ្លះនៃបឹងសម្រាប់សំណង់លំនៅឋានប្រជាពលរដ្ឋ និងការអភិវឌ្ឍគម្រោងអចលនទ្រព្យផ្សេងៗទៀត។ ការសិក្សាវាយតម្លៃរបស់ក្រុមនេះបានកំណត់ឃើញបញ្ហាប្រឈមជាច្រើន ដូចជា ការគ្រប់គ្រងសំណល់រឹង ក្លិនភាយចេញពីសំណល់រឹង រាវ និងការលុបបឹងដើម្បីសាងសង់លំនៅឋាន និងគម្រោងសំណង់ថ្មីៗ។ បន្ថែមលើនេះ តំបន់នោះរងគ្រោះទឹកជំនន់នៅរដូវវស្សា ដោយសារការកកស្ទះសំណល់រឹងនៅតាមប្រឡាយ។ បញ្ហានេះបានបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ បរិស្ថាន សុខុមាលភាពប្រជាពលរដ្ឋ អនាម័យ ព្រមទាំងទេសភាព នៅតំបន់នោ។ ក្រុមនេះបានបង្ហាញអំពីគំនិត ដើម្បីកែលម្អតំបន់នោះ ដូចជា ការស្តារប្រឡាយ ការអភិវឌ្ឍផ្លូវ និងផ្លូវអ្នកថ្មើរជើងនៅតាមបណ្តោយប្រឡាយ ព្រមទាំងសួនច្បារសាធារណៈ ការបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់រឹង ការចិញ្ចឹមត្រី និងការដាំកំប្លោកដើម្បីកាត់បន្ថយក្លិន។ គំនិតកែលម្អប្រឡាយនេះនឹងផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្បែរតំបន់នោះតាមរយៈការធ្វើបរិស្ថានរស់នៅកាន់តែមានផាសុកភាពជាមួយនឹងការរៀបចំលំហសាធារណៈឬសួនច្បារបៃតង ផ្លូវ និងផ្លូវអ្នកថ្មើរជើង ព្រមទាំងកន្លែងកម្សាន្ត។

**មហាវិថីព្រះនរោត្តមពីវិមានឯករាជ្យ (ផ្លូវលេខ ៤១) ឆ្ពោះទៅរមណីយដ្ឋានវត្តភ្នំ**

*លោក តែ ម៉េឡូឌី*

ក្រុមនេះបានបង្ហាញគម្រោងមហាវិថីព្រះនរោត្តមដែលជាមហាវិថីដ៏សំខាន់មួយតភ្ជាប់តំបន់សំខាន់ផ្សេងៗនៅក្នុងរាជធានីភ្នំពេញ ដូចជាអគារ និងតំបន់ពាណិជ្ជកម្ម សេវាកម្មសាធារណៈ ទីតាំងប្រវត្តិសាស្ត្រ សួនច្បារសាធារណៈ និងកន្លែងកម្សាន្ត។ ទោះជាយ៉ាងណាក្តី មានបញ្ហាប្រឈមនានានៅតាមមហាវិថីនេះ ដូចជា ការប្រើប្រាស់ទីធ្លាសាធារណៈ និងផ្លូវថ្មើរជើងមិនត្រឹមត្រូវ កង្វះទីធ្លាសាធារណៈដែលប្រជាពលរដ្ឋអាចលំហែជាមួយនឹងធម្មជាតិ កង្វះសម្ភារៈ (ឧ. តុ បង់អង្គុយលេង) និងរុក្ខជាតិ (ឧ. ដើមឈើ និងផ្កា)។ សម្រាប់ការអភិវឌ្ឍនគរូបនីយកម្មប្រកបដោយចីរភាព និងបរិយាបន្ន ក្រុមនេះបានផ្តោតលើសារៈសំខាន់នៃការពិចារណាលើទិដ្ឋភាពជាច្រើន ដូចជា ចំណុចដែលមានទេសភាពស្អាតសម្រាប់រៀបចំសួនច្បារ និងលំហបៃតង ការរចនា និងរចនាសម្ព័ន្ធដែលយកចិត្តទុកដាក់ចំពោះតម្រូវការសហគមន៍ជាចម្បង ការតាំងបង្ហាញអំពីវប្បធម៌ប្រវត្តិសាស្ត្រ និងការតភ្ជាប់ជាមួយនឹងប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដូចជា រថយន្តក្រុង គន្លងសម្រាប់កង់ និងផ្លូវថ្មើរជើង។ ជាពិសេស ក្រុមនេះបានស្នើគំនិតមួយចំនួនដើម្បីធ្វើឱ្យមហាវិថីព្រះនរោត្តមកាន់តែប្រសើរឡើង ដូចជា ការតម្លើងប្រព័ន្ធប្រើប្រាស់ថាមពលព្រះអាទិត្យសម្រាប់ដំណើរការផ្ទាំងផ្សព្វផ្សាយអំពីវប្បធម៌កម្ពុជា និង ប្រព័ន្ធស្រោចស្រពរុក្ខជាតិ ការរចនាសិល្បៈតាមដងមហាវិថី ការកែលម្អចំណតរថយន្តក្រុងជាមួយនឹងផ្ទាំងផ្សាយពាណិជ្ជកម្ម និងជញ្ជាំងបៃតង និងការរៀបចំពិពណ៌ខ្ចីជីថលនៅជិតរមណីយដ្ឋានវត្តភ្នំ។ គំនិតទាំងនេះនឹងប្រែក្លាយមហាវិថីព្រះនរោត្តមទៅជាមហាវិថីដែលមានមនុស្សកាន់តែច្រើន និងមិនបង្កផលប៉ះពាល់ចំពោះបរិស្ថាន។

**មហាវិថីព្រះមុនីវង្សពីស្តុបពេទ្យចិន (ផ្លូវលេខ ៩៣) ឆ្ពោះទៅស្តាតចាស់**

*លោក ចន្ទី ម៉ានីរ័ត្ន*

ក្រុមនេះបានបង្ហាញគំនិតដើម្បីកែលម្អមហាវិថីព្រះមុនីវង្ស ដែលជាមហាវិថីដ៏មមាញឹកមួយ មានអគារ និងតំបន់ពាណិជ្ជកម្មជាច្រើន រួមទាំងផ្សារថ្មីផងដែរ។ ដោយផ្អែកលើការអង្កេតតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ព្រមទាំងការវិភាគលើកំណត់ត្រាអំពីអ្នកថ្មើរជើង និងការប្រើប្រាស់រថយន្តក្រុង ក្រុមបានស្នើគំនិតដែលមិនត្រឹមតែដោះស្រាយភាពមមាញឹកដែលមានស្រាប់ប៉ុណ្ណោះឡើយ ប៉ុន្តែក៏ប្រែក្លាយមហាវិថីមុនីវង្សទៅជាមហាវិថីបៃតងសម្រាប់អ្នកថ្មើរជើង និងការធ្វើដំណើរទៅកាន់តំបន់ពាណិជ្ជកម្ម និងតំបន់ទេសចរណ៍នានាផងកាន់តែងាយស្រួល។ ក្រុមនេះបានចែករំលែកគំនិតរបស់ខ្លួនដើម្បីកែលម្អការធ្វើដំណើរដោយបែងចែកគន្លងផ្លូវសម្រាប់រថយន្តក្រុង គន្លងសម្រាប់រថយន្ត និងទោចក្រយានយន្ត គន្លងសម្រាប់កង់ និងគន្លងសម្រាប់ជនមានពិការភាពភ្នែក។ ក្រុមនេះក៏បានស្នើអំពីការតម្លើងអំពូលសូឡានៅតាមដងផ្លូវពាណិជ្ជកម្ម ផ្លូវតូចៗ ចំណុចប្រសព្វ ដើម្បីធ្វើឱ្យមហាវិថីនេះកាន់តែមានសុវត្ថិភាពសម្រាប់អ្នកថ្មើរជើង និងអ្នកធ្វើដំណើរ។ ការសាងសង់ស្ពាន និងផ្លូវកាត់ក្រោមដី សម្រាប់អ្នកថ្មើរជើងក៏បានលើកឡើងផងដែរ ដើម្បីកាត់បន្ថយការកកស្ទះនៅតាមមហាវិថីនេះផងដែរ។ ដើម្បីកែលម្អមហាវិថីនេះដោយឈរលើគោលការណ៍មិនបង្កផលប៉ះពាល់ដល់បរិស្ថាន និងសេដ្ឋកិច្ចក្រា ក្រុមក៏បានលើកឡើងអំពីការជួសជុលសួនច្បារ និងឧទ្យានសាធារណៈឡើងវិញ គំនិតផ្តួចផ្តើមប្រើប្រាស់កង់សាធារណៈ កន្លែងផ្តល់សេវាកម្ម (ឧទា. ម៉ាស៊ីនលក់ឥវ៉ាន់ ATM) ការបង្កើនចំណត និងការរៀបចំហាងទំនេរសម្រាប់គោលបំណងផ្សេងទៀត។




## សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងតំបន់ជុំវិញ

*លោក នូវ មុនីរតន៍*

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង គឺជាសារមន្ទីរប្រវត្តិសាស្ត្រ ដែលជាអតីតសាលារៀនមធ្យមសិក្សា និងត្រូវបានប្រើប្រាស់ជាពន្ធនាគារស២១ក្នុងរបបខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ការដួលរលំនៅឆ្នាំ១៩៧៩។ ទោះជាសារមន្ទីរនេះហ៊ុំព័ទ្ធទៅដោយតំបន់ពាណិជ្ជកម្ម ផ្សារ និងស្ថាប័នអប់រំ តំបន់នេះជួបប្រទះបញ្ហាប្រឈមសង្គម ដូចជាការស្ទះចរាចរណ៍ ការប្រើប្រាស់ដីមិនមានប្រសិទ្ធភាព ឧទ្យានឬលំហបៃតងសាធារណៈនៅមានកម្រិត និងឥទ្ធិពលនៃកំណើនកម្តៅ។ ដូច្នេះ ក្រុមនេះបានស្នើឱ្យកែលម្អតំបន់ជុំវិញសារមន្ទីរនេះដោយកំណត់តំបន់នេះជាតំបន់ដែលអនុញ្ញាតល្បឿនបើកបរត្រឹម ១០គ.ម ក្នុងមួយម៉ោង និងមិនអនុញ្ញាតឱ្យរថយន្តដឹកទំនិញចូល។ សារមន្ទីរនេះផ្ទាល់ក៏គប្បីត្រូវកែលម្អ ការធ្វើទីផ្សារឬការចែករំលែកព័ត៌មានអំពីសារមន្ទីរនេះ ប្រព័ន្ធគ្រប់គ្រងសំណល់រឹង ការប្រើប្រាស់លំហផ្លូវសាធារណៈនៅមុខសារមន្ទីរ និងកន្លែងដាក់ភ្ញៀវឱ្យបានត្រឹមត្រូវផងដែរ។ នៅចុងបញ្ចប់នៃបទបង្ហាញ ក៏បានគូសបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចសហការរវាងរដ្ឋ និងឯកជន ក្នុងការកែលម្អតំបន់ជុំវិញសារមន្ទីរប្រវត្តិសាស្ត្រនេះ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ឱ្យបានកាន់តែច្រើនបន្ថែមទៀត។



## សារមន្ទីរប្រល័យពូជសាសន៍ជើងឯក និងតំបន់ជុំវិញ

*លោក គួ កែវវិបុល*

វេទិកាជាតិលើកទី២ ស្តីពី
"ទីក្រុង និងលំនៅឋាន"

សារមន្ទីរប្រល័យពូជសាសន៍ជើងឯក គឺជាទីតាំងប្រវត្តិសាស្ត្រ ព្រមទាំងទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ។ ទោះជាយ៉ាងណាក្តី សារមន្ទីរនេះប្រឈមនឹងបញ្ហាមួយចំនួន ដូចជា សេវាកម្មនៅមានកម្រិតអប្បបរមា ការផ្សាយពាណិជ្ជកម្មមិនគ្រប់គ្រាន់ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ និងមានការរំខានដោយសម្លេងរថយន្តដឹកទំនិញ និងយានយន្តនៅលើដងផ្លូវធំ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ព្រមទាំង ធ្វើឱ្យសេវាកម្មកាន់តែប្រសើរឡើង និងទាក់ទាញភ្ញៀវទេសចរណ៍ ក្រុមនេះបានស្នើបង្កើនចំនួនដើមឈើ និងបង្កើតសួនច្បារតូចៗ ព្រមទាំងកន្លែងលេងកម្សាន្តសម្រាប់កុមារ ស្របពេលដែលបំពាក់បច្ចេកទេសវិទ្យាឌីជីថលឆ្លាត ដូចជា ប្រព័ន្ធQRកូដ បច្ចេកវិទ្យាAR បច្ចេកវិទ្យាVR និងហូឡូក្រាមនៅក្នុងសារមន្ទីរ។






# វគ្គទី៦៖ កម្មវិធីបិទវេទិកា



វេទិកានេះបានបញ្ចប់ជាមួយនឹងសេចក្តីថ្លែងការណ៍អំពីអាទិភាពសំខាន់ៗ និងជំហានបន្ទាប់ក្នុងការធ្វើកិច្ចសហការគ្នាដើម្បីអភិវឌ្ឍទីក្រុងឆ្លាត បៃតង ប្រកបដោយចីរភាព និងបរិយាបន្ននៅកម្ពុជា។

## វាគ្មិន

- **លោក** Joseph Scheuer អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា
- **លោកស្រី** Yoonhee Kim ប្រធានអនុវត្តសម្រាប់ទីក្រុង ភាពធន់ និងដីធ្លីប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកនៃធនាគារពិភពលោក
- **ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ** អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
- **ឯកឧត្តម តឹករ៉េត សំរេច** រដ្ឋលេខាធិការប្រចាំការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សេចក្តីសង្ខេប

### សុន្ទរកថាដោយតំណាងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា

*លោក Joseph Scheuer អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា*

លោក Scheuer បានគូសបញ្ជាក់អំពីចំណុចសំខាន់នៃអនាគតនគរូបនីយកម្មប្រកបដោយចីរភាពដោយផ្តោតការយកចិត្តទុកដាក់លើតម្រូវការប្រជាពលរដ្ឋជាចម្បងតាមរយៈប្រសិទ្ធភាពនៃភាពជាដៃគូរវាងភាគីពាក់ព័ន្ធគ្រប់គ្នាក្នុងការអភិវឌ្ឍទីក្រុង និងលំនៅឋានរបស់ប្រជាពលរដ្ឋ សំដៅសម្រេចបាននូវវិបុលភាពរយៈពេលវែងសម្រាប់ប្រជាពលរដ្ឋទាំងអស់នៅកម្ពុជា។ ដើម្បីឱ្យនគរូបនីយកម្មប្រកបដោយចីរភាពដោយមិនទុកនរណាម្នាក់ចោល លោកបានចែករំលែកអំពីវិស័យជាយុទ្ធសាស្ត្រចំនួនបួន ដើម្បីជំរុញការអភិវឌ្ឍទីក្រុងឆ្លាត បៃតង ប្រកបដោយចីរភាព និងបរិយាបន្ន៖ (១) ការពង្រឹង និងការជំរុញបច្ចេកវិទ្យាទីក្រុងឆ្លាត និងយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងអភិបាលកិច្ចទីក្រុង ការរៀបចំផែនការ និងការគ្រប់គ្រង (២) ការជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មដែលមានភាពធន់ រួមទាំងដំណោះស្រាយដោយផ្អែក

លើធម្មជាតិ (៣) ការវិនិយោគលើការអភិវឌ្ឍដីធ្លី និងលំនៅឋាតម្លៃសមរម្យ រួមទាំងការជំរុញការរចនាលំនៅឋានជាមួយនឹងដំណោះស្រាយអកម្មផ្តល់ភាពត្រជាក់ (passive cooling solutions) និងបច្ចេកវិទ្យាអគារបៃតង ព្រមទាំង (៤) ការប្រមូល និងការចែករំលែកទិន្នន័យទិដ្ឋភាពទីក្រុងផ្សេងៗ ប្រកបដោយនវានុវត្តន៍ និងឆ្លាត។ លោកក៏បានសង្កត់ធ្ងន់ថា លទ្ធផលជាអតិបរមានៃកិច្ចអន្តរាគមន៍នានាអាចនឹងសម្រេចបានតាមរយៈការពង្រឹងភាពជាដៃគូ រវាងភាគីពាក់ព័ន្ធជាច្រើន ដោយយកចិត្តទុកដាក់លើការអនុវត្តនវានុវត្តន៍ និងបច្ចេកវិទ្យា ព្រមទាំងការពង្រឹងការយល់ដឹង និងសមត្ថភាពរបស់ភាគីពាក់ព័ន្ធ។



## សុន្ទរកថាដោយធនាគារពិភពលោក

*លោកស្រី Yoonhee Kim ប្រធានអនុវត្តសម្រាប់ទីក្រុងភាពធន់ និងដីធ្លីប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកនៃធនាគារពិភពលោក*

លោកស្រី Kim បានថ្លែងអំណរគុណដល់អ្នកសហរៀបចំវេទិកា និងអ្នកចូលរួមទាំងអស់សម្រាប់កិច្ចសន្ទនា និងការពិភាក្សាយ៉ាងសកម្ម ដើម្បីសម្រេចបានការអភិវឌ្ឍទីក្រុងឆ្លាត បៃតង ប្រកបដោយចីរភាព និងបរិយាបន្នទៅកម្ពុជា។ តាមរយៈកិច្ចពិភាក្សាអំពីបញ្ហាប្រឈម និងកាលានុវត្តភាពពាក់ព័ន្ធនឹងនគរូបនីយកម្មជាតិ អ្នកចូលរួមអាចរៀនសូត្រអំពីគំនិតគួរឱ្យចាប់អារម្មណ៍ជាច្រើនពាក់ព័ន្ធនឹងការដាក់បញ្ចូលភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅក្នុងការរៀបចំផែនការប្រើប្រាស់ដី ដំណោះស្រាយលំនៅឋានតម្លៃសមរម្យ ក្របខណ្ឌទីក្រុងឆ្លាត នវានុវត្តន៍ និងបច្ចេកវិទ្យា។ ប្រធានបទទាំងអស់នេះមានទំនាក់ទំនងទៅវិញទៅមក និងជាប្រធានបទចាំបាច់ក្នុងការប្រើប្រាស់នគរូបនីយកម្មជាកត្តាជំរុញការអភិវឌ្ឍមូលធនមនុស្ស និងរបៀងសេដ្ឋកិច្ចនៅក្នុងប្រទេស។ នវានុវត្តន៍ និងបច្ចេកវិទ្យាមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈម ហើយឌីជីថលូបនីយកម្មគប្បីត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធអភិបាលកិច្ច។ ដើម្បីបន្តជំហានឆ្ពោះទៅមុខ លោកស្រីបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការអនុវត្តយុទ្ធសាស្ត្រភាពជាដៃគូជាមួយនឹងតួអង្គផ្សេងៗ ទាំងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍។



## សុន្ទរកថាបូកសរុបលទ្ធផល

*ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*

ឯកឧត្តមបណ្ឌិត ខេមរ៉ូ បានរំលឹកអំពីគោលបំណងនៃវេទិកានេះ និង កោតសរសើរដល់អ្នកចូលរួមចំពោះការយកចិត្តទុកដាក់លើបទបង្ហាញ កិច្ចសន្ទនា និងកិច្ចពិភាក្សារយៈពេលមួយថ្ងៃកន្លះកន្លងមកនេះ។ ឯកឧត្តមបានចាត់ទុកវេទិកាជាតិលើកទី២ស្តីពី "ទីក្រុង និងលំនៅឋាន" នេះថាជាឱកាសសំខាន់មួយក្នុងការជំរុញកិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធ ដើម្បីពិចារណា និងកំណត់ដំណោះស្រាយដ៏សក្តិសម និងប្រកបដោយសក្តានុពល ឆ្លើយតបនឹងបញ្ហាប្រឈមដែលកម្ពុជាកំពុងជួបប្រទះ ដោយសារការអភិវឌ្ឍ នគរូបនីយកម្ម និងលំនៅឋាននាពេលបច្ចុប្បន្នក្នុងទីក្រុង។ ឯកឧត្តមក៏កោតសរសើរចំពោះការប្តេជ្ញាចិត្តរបស់ដៃគូអភិវឌ្ឍន៍ក្នុងការបន្តភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការជាមួយ

រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចឱ្យបានការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព និងបរិយាបន្ន ស្របតាម ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ឯកឧត្តមបានលើកទឹកចិត្តអ្នកចូលរួមទាំងអស់ឱ្យចូលរួមនៅក្នុងដំណើរអភិវឌ្ឍន៍អនាគតទីប្រជុំជនប្រកបដោយចីរភាព និងបរិយាបន្ននៅកម្ពុជាតាមរយៈការអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ បច្ចេកវិទ្យាទិន្នន័យភូមិសាស្ត្រ ប្រព័ន្ធចែករំលែកទិន្នន័យ លំនៅឋានតម្លៃសមរម្យ និងហិរញ្ញប្បទាន ព្រមទាំងភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ឯកឧត្តមក៏ថ្លែងអំណរគុណម្ចាស់ជ័យលាភីនៃកម្មវិធីប្រឡងប្រណាំង ដែលបានចែករំលែកគំនិតនានាក្នុងការកែលម្អទីតាំងមួយចំនួនដែលត្រូវបានជ្រើសរើសនៅរាជធានីភ្នំពេញ។ ការចូលរួមរបស់ភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងយុវជន គឺជាការចាំបាច់ដើម្បីអភិវឌ្ឍអនាគតទីប្រជុំជនប្រកបដោយចីរភាព និងបរិយាបន្ននៅកម្ពុជា។

## សុន្ទរកថាបិទវេទិកា និងពិធីប្រគល់រង្វាន់ និងប័ណ្ណសរសើរ

*ឯកឧត្តម តឹករ៉េត សំរេច រដ្ឋលេខាធិការប្រចាំការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

ឯកឧត្តម សំរេច បានសម្តែងសេចក្តីថ្លែងអំណរគុណចំពោះការរៀបចំវេទិកាជាតិលើកទី២ស្តីពី "ទីក្រុងនិងលំនៅឋាន" នៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មទី៤ ដែលបានផ្តល់ឱកាសឱ្យយើងប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីពន្លឿនការអភិវឌ្ឍជាតិ។ វេទិកានេះ គឺជាឱកាសដ៏ល្អសម្រាប់អ្នកចូលរួមចែករំលែកការអនុវត្ត និងបទពិសោធន៍ល្អៗ ចូលរួមនៅក្នុងកិច្ចសន្ទនា និងពិចារណាលើការអភិវឌ្ឍទីប្រជុំជននៅពេលអនាគតសំដៅសម្រេចបានចក្ខុវិស័យកម្ពុជាសម្រាប់ឆ្នាំ២០៣០ និង២០៥០។ វេទិកានេះបានផ្តល់ជាធាតុចូលបន្ថែមដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមនគរូបនីយកម្ម និងលំនៅឋាន ព្រមទាំងធ្វើសុខដុមនីយកម្មផែនការអភិវឌ្ឍន៍ទីក្រុង និងលំនៅឋានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ឯកឧត្តមបានចែករំលែកចំណុចមួយចំនួនសម្រាប់ការអភិវឌ្ឍនៅកម្ពុជានាពេលអនាគត ដូចជា (១) ការអភិវឌ្ឍប្រកបដោយភាពទាក់ទាញ មានអនាម័យ និងភាពរៀបរយ (២) ផែនការរចនាប្រព័ន្ធលូ និងការប្រើប្រាស់ដីដ៏ត្រឹមត្រូវ (៣) ការពង្រឹងប្រសិទ្ធភាពនៃការពិនិត្យតាមដាន អធិការកិច្ច និងការវាយតម្លៃការគ្រប់គ្រងដីធ្លី និងការងារទីក្រុង និង (៤) ការបន្សុីគម្រោង និងការវិនិយោគនានាឱ្យស្របទៅតាមផែនការប្រើប្រាស់ដី។ នៅចុងបញ្ចប់នៃវេទិកាជាតិលើកទី២ស្តីពី "ទីក្រុង និងលំនៅឋាន" ឯកឧត្តមក៏បានលើកឡើងអំពីអនុសាសន៍របស់ឯកឧត្តមឧបនាយករដ្ឋមន្រ្តីថាត្រូវបង្កើត "ទីក្រុងគួរឱ្យចង់រស់នៅ និងល្អសម្រាប់ប្រជាពលរដ្ឋទាំងអស់ រួមទាំងជនបរទេស" ។



# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១៖ របៀបវារៈនៃវេទិកាជាតិលើកទី២ស្តីពី "ទីក្រុង និងលំនៅឋាន"

| ម៉ោង | កម្មវិធី | វាគ្មិន |
|---|---|---|
| **កាលបរិច្ឆេទ៖ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤** | | |
| ៨:០០-៨:៣០ | ការចុះឈ្មោះ | អគ្គនាយកដ្ឋានរដ្ឋបាល |
| វគ្គទី១៖ ការបើកវេទិកា | | |
| ៨:៣០-៨:៣៥ | គោរពភ្លេងជាតិ និងកិច្ចចាប់ផ្តើមកម្មវិធី | ពិធីករ |
| ៨:៣៥-៨:៤៥ | ចាក់បញ្ចាំងវីដេអូខ្លីស្តីពីការងាររៀបចំដែនដី នគរូបនីយកម្ម និងលំនៅឋាននៅកម្ពុជា | ក្រុមការងារប្រព័ន្ធផ្សព្វផ្សាយ |
| ៨:៤៥-៨:៥៥ | សុន្ទរកថាដោយតំណាង UN-Habitat | លោក Srinivasa POPURI ប្រធានកម្មវិធី ទីក្រុងបាងកក ការិយាល័យកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក |
| ៨:៥៥-៩:០៥ | សុន្ទរកថាដោយតំណាងធនាគារពិភពលោក | លោកស្រី Maryam Salim ប្រធានធនាគារពិភពលោកប្រចាំកម្ពុជា |
| ៩:០៥-៩:១៥ | សុន្ទរកថាដោយតំណាងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម |
| ៩:១៥-៩:៣៥ | សុន្ទរកថាបើកដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ៩:៣៥-៩:៥០ | ការថតរូបជុំគ្នា និងសម្រាកពិសារអាហារសម្រន់ | |
| **វគ្គទី២៖ ការធ្វើបទបង្ហាញដោយអគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម**<br>***សម្របសម្រួលដោយ ឯកឧត្តម យី យ៉ាណារតន៍ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*** | | |
| ៩:៥០-១០:៣០ | ការរៀបចំដែនដីនៅកម្ពុជា៖ វឌ្ឍនភាព និងគន្លឹះឆ្ពោះទៅមុខ (គោលបំណង យន្តការ ការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃ) | ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម |
| ១០:៣០-១១:០០ | ក្របខណ្ឌច្បាប់ និងគតិយុត្តស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម | ឯកឧត្តមបណ្ឌិត ម៉េង ប៊ុណ្ណារិទ្ធ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម |
| ១១:០០-១១:៣០ | ករណីសិក្សាស្តីពីការរៀបចំប្លង់គោលប្រើប្រាស់ដីស្រុកសេសាន ខេត្តស្ទឹងត្រែង និងសង្កាត់អណ្តូងខ្មែរ ក្រុងកំពត ខេត្តកំពត | ឯកឧត្តមបណ្ឌិត សារ៉េត ប៉ូរ៉ាមី អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម |
| ១១:៣០-១២:០០ | សំណួរ-ចម្លើយ | |

| | | |
|---|---|---|
| ១២:០០-១៣:០០ | សម្រាកពិសាអាហារថ្ងៃត្រង់ (អាហារដ្ឋានក្រសួង) | |
| **វគ្គទី៣៖ ការធ្វើបទបង្ហាញដោយដៃគូអភិវឌ្ឍន៍**<br>***សម្របសម្រួលដោយ ឯកឧត្តម ម៉េង ប៊ុណ្ណារិទ្ធ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*** | | |
| ១៣:០០-១៣:២០ | ទីក្រុងគួរឱ្យចង់រស់នៅសម្រាប់អនាគតរបស់កម្ពុជា | លោក Andre A. Bald ប្រធានក្រុមដឹកនាំអ្នកឯកទេសផ្នែកទីក្រុងនៃធនាគារពិភពលោក |
| ១៣:២០-១៣:៤០ | របកគំហើញសំខាន់ៗពីគំនិតផ្តួចផ្តើមទីក្រុងប្រកបដោយចីរភាពនៅកម្ពុជា៖ អន្តរកាលឆ្ពោះទៅរកការបញ្ចេញកាបូនទាប និងមធ្យោបាយធន់នឹងអាកាសធាតុ | លោកស្រី Jessica Schmidt អ្នកឯកទេសផ្នែកទីក្រុងនៃធនាគារពិភពលោក |
| ១៣:៤០-១៤:០០ | ការវាយតម្លៃដី និងអចលទ្រព្យសម្រាប់ការប្រមូលពន្ធនៅអាស៊ាន | លោក Stamatis Kotouzas អ្នកឯកទេសជាន់ខ្ពស់ផ្នែករដ្ឋបាលដីធ្លីនៃធនាគារពិភពលោក |
| ១៤:០០-១៤:២០ | របកគំហើញសំខាន់ៗពីរបាយការណ៍វាយតម្លៃទីក្រុងឆ្លាតផែនទីបង្ហាញផ្លូវទីក្រុងឆ្លាតថ្នាក់ជាតិ ការបង្កើតយុទ្ធសាស្ត្រទីក្រុងឆ្លាតថ្នាក់ជាតិ និងសំណើយុទ្ធសាស្ត្រទីក្រុងឆ្លាតសម្រាប់ខេត្តព្រះសីហនុ | លោក សុខ វណ្ណា និងលោក Sangmin Nam តំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ (UNESCAP, UN-Habitat, UNOPS) |
| ១៤:២០-១៤:៤០ | ការចែករំលែកបទពិសោធន៍ និងគំនិតសក្តានុពលសម្រាប់ដំណោះស្រាយផ្អែកលើធម្មជាតិនៅក្នុងការសាងសង់លំនៅឋានមិនផ្លូវការ | លោក Jun Fujihira មន្ត្រីកម្មវិធីនៃអង្គការ UN-Habitat ប្រចាំកម្ពុជា |
| ១៤:៤០-១៥:០០ | ផែនការរៀបចំដែនដី៖ ជំរុញសមាហរណកម្មអន្តរវិស័យសម្រាប់ការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព | លោក Alvin Lopez អ្នកឯកទេសជាន់ខ្ពស់ផ្នែកធនធានធម្មជាតិ និងកសិកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី |
| ១៥:០០-១៥:៣០ | សំណួរ-ចម្លើយ | |
| ១៥:៣០-១៥:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:៤៥–១៦:០០ | បូកសរុបលទ្ធផលថ្ងៃទី១ | សេចក្តីសង្ខេបលទ្ធផលដោយក្រុមលេខាធិការដ្ឋាន |
| **កាលបរិច្ឆេទ៖ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤** | | |
| ៨:០០-៨:៣០ | ការចុះឈ្មោះ | អគ្គនាយកដ្ឋានរដ្ឋបាល |
| ៨:៣០-៨:៣៥ | សង្ខេបលទ្ធផលថ្ងៃទី១ | សេចក្តីសង្ខេបលទ្ធផលដោយក្រុមលេខាធិការដ្ឋាន |
| **វគ្គទី៤៖ ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យនៅកម្ពុជា**<br>***សម្របសម្រួលដោយ ឯកឧត្តម ឈឹម សុគន្ធ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម*** | | |
| ៨:៣៥-៩:០០ | ស្ថានភាពលំនៅឋានតម្លៃសមរម្យនៅក្នុងទីក្រុងនៅកម្ពុជា | លោក សុខ សំអូន អគ្គនាយករងនៃអគ្គនាយកដ្ឋានលំនៅឋាន |

| | | |
|---|---|---|
| ៩:00-៩:១៥ | វិស័យលំនៅឋាននៅកម្ពុជា៖ ទិដ្ឋភាពទូទៅនៃទីផ្សារ និងឧត្តមានុវត្តន៍ថ្នាក់តំបន់ | លោកស្រី Dao Harrison អ្នកឯកទេសជាន់ខ្ពស់ផ្នែកលំនៅឋាននៃធនាគារពិភពលោក |
| ៩:១៥-៩:៣០ | គម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ "ទីក្រុងរណមសិរីមង្គល" | លោក យក់ សុធីរិទ្ធ នាយកគ្រប់គ្រងនៃក្រុមហ៊ុន World Bridge Homes Co., Ltd. |
| ៩:៣០-៩:៤៥ | សំណួរ-ចម្លើយ | |
| ៩:៤៥-១០:00 | សម្រាកពិសាអាហារសម្រន់ | |
| **វគ្គទី៥៖ ការធ្វើបទបង្ហាញដោយបេក្ខជនភ័យលាភីស្តីពីការរចនានគរូបនីយកម្ម**<br>***សម្របសម្រួលដោយ ឯកឧត្តម សេក សុធីរិទ្ធ ប្រធាននាយកដ្ឋាននគរូបនីយកម្ម*** | | |
| ១០:00-១០:១៥ | ប្រធានបទ៖ គម្រោងកែលម្អទេសភាពប្រឡាយតាមបណ្ដោយផ្លូវលេខ ៣០៧ | តំណាងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម |
| ១០:១៥-១០:៣០ | ប្រធានបទ៖ មហាវិថីព្រះនរោត្តមពីវិមានឯករាជ្យ (ផ្លូវលេខ ៤១) ឆ្ពោះទៅរមណីយដ្ឋានវត្តភ្នំ | តំណាងក្រុម |
| ១០:៣០-១០:៤៥ | ប្រធានបទ៖ មហាវិថីព្រះមុនីវង្សពីស្តុបពេទ្យចិន (ផ្លូវលេខ ៩៣) ឆ្ពោះទៅស្ពានចាស់ | តំណាងក្រុម |
| ១០:៤៥-១១:00 | ប្រធានបទ៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងតំបន់ជុំវិញ | តំណាងក្រុម |
| ១១:00-១១:១៥ | ប្រធានបទ៖ សារមន្ទីរប្រល័យពូជសាសន៍ជើងឯក និងតំបន់ជុំវិញ | តំណាងក្រុម |
| ១១:១៥-១១:៣០ | សំណួរ-ចម្លើយ | |
| **វគ្គទី៦៖ ការបិទវេទិកា** | | |
| ១១:៣០-១១:៤០ | សុន្ទរកថាដោយតំណាងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា | លោក Joseph Scheuer អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា |
| ១១:៤០-១១:៥០ | សុន្ទរកថាដោយតំណាងធនាគារពិភពលោក | លោកស្រី Yoonhee Kim ប្រធានអនុវត្តសម្រាប់ទីក្រុង ភាពធន់ និងដីធ្លីប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកនៃធនាគារពិភពលោក |
| ១១:៥០-១២:00 | សុន្ទរកថាបូកសរុបលទ្ធផលដោយតំណាងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម | ឯកឧត្តម បេងហុង សុជាតិ ខេមរ៉ូ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម |
| ១២:00 | សុន្ទរកថាបិទវេទិកា និងពិធីប្រគល់រង្វាន់ និងលិខិតសរសើរ | **ឯកឧត្តម តឹករ៉េត សំរេច** រដ្ឋលេខាធិការប្រចាំការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

## ឧបសម្ព័ន្ធ ២៖ បញ្ជីអ្នកចូលរួម

** តម្រៀបទៅតាមលំដាប់លំដោយតួអក្សរ*

| ស្ថាប័ន | អ្នកចូលរួម |
|---|---|
| **ក. ក្រសួង និងស្ថាប័នរដ្ឋាភិបាល** | **១៣៩រូប** |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០៦រូប |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប |
| ក្រសួងពាណិជ្ជកម្ម | ១រូប |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១រូប |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២រូប |
| ក្រសួងអប់រំ យុវជន និងកីឡា | ១រូប |
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១រូប |
| ក្រសួងមហាផ្ទៃ | ២រូប |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១រូប |
| ក្រសួងរ៉ែ និងថាមពល | ១រូប |
| ក្រសួងការពារជាតិ | ១រូប |
| ក្រសួងផែនការ | ១រូប |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១រូប |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | ១រូប |
| ក្រសួងព្រះបរមរាជវាំង | ១រូប |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប |
| ក្រសួងទេសចរណ៍ | ២រូប |
| ក្រសួងធនធានទឹក និងឧតុនិយម | ១រូប |
| អាជ្ញាធរជាតិអប្សរា | ១រូប |
| គណៈវិស្វករកម្ពុជា | ៣រូប |
| អាជ្ញាធរជាតិព្រះវិហារ | ១រូប |
| អាជ្ញាធរជាតិសំបូរព្រៃគុក | ១រូប |
| ទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប |
| រាជបណ្ឌិត្យសភាកម្ពុជា | ២រូប |
| **ខ. មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រាជធានី ខេត្ត** | **៣៣រូប** |
| **គ. រដ្ឋបាលរាជធានី ខេត្ត** | **២៤រូប** |
| **ឃ. ទីភ្នាក់ងារអង្គការសហប្រជាជាតិ** | **១៣រូប** |
| ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ | ២រូប |
| មូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) | ១រូប |

| ស្ថាប័ន | អ្នកចូលរួម |
|---|---|
| គណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (UNESCAP) | ១រូប |
| កម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UN-Habitat) | ៥រូប |
| ការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាកម្មគម្រោង (UNOPS) | ៣រូប |
| កម្មវិធីអង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (UNAIDS) | ១រូប |
| **ង. ដៃគូអភិវឌ្ឍន៍** | **១៦រូប** |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៤រូប |
| សហភាពអឺរ៉ុប (EU) | ១រូប |
| ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការប្រទេសជប៉ុន (JICA) | ១រូប |
| ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) | ១រូប |
| ធនាគារពិភពលោក (WB) | ៩រូប |
| **ច. ស្ថានទូតបរទេស** | **៥រូប** |
| ស្ថានទូតអូស្ត្រាលី | ១រូប |
| ស្ថានទូតជប៉ុន | ១រូប |
| ស្ថានទូតរុស្ស៊ី | ១រូប |
| ស្ថានទូតសាធារណរដ្ឋឆេក | ១រូប |
| ស្ថានទូតវៀតណាម | ១រូប |
| **ឆ. អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល** | **១១រូប** |
| អង្គការមូលនិធិអាស៊ី | ១រូប |
| វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) | ១រូប |
| វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាអំពីទីក្រុង (CIUS) | ១រូប |
| អង្គការក្រុមការងារពង្រឹង និងអភិវឌ្ឍសហគមន៍ | ១រូប |
| អង្គការមិត្តសំឡាញ់ | ១រូប |
| អង្គការ GIZ | ២រូប |
| អង្គការលំនៅឋានមនុស្សជាតិកម្ពុជា | ១រូប |
| វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា | ១រូប |
| អង្គការ People In Need | ១រូប |
| អង្គការវ៉តធីអេតកម្ពុជា | ១រូប |
| **ជ. ស្ថាប័នអប់រំសិក្សាធិការ និងគ្រឹះស្ថានស្រាវជ្រាវ** | **៤៧រូប** |
| សាកលវិទ្យាល័យអាមេរិកាំងភ្នំពេញ | ១រូប |
| វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាអំពីទីក្រុង | ២រូប |
| សាកលវិទ្យាល័យអន្តរជាតិ | ១រូប |
| សាកលវិទ្យាល័យលីមកុកវិញ | ១រូប |
| សាកលវិទ្យាល័យជាតិគ្រប់គ្រង | ៣រូប |

វេទិកាជាតិលើកទី២ ស្តីពី
"ទីក្រុង និងលំនៅឋាន"

| ស្ថាប័ន | អ្នកចូលរួម |
|---|---|
| វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប - NIA | ២រូប |
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ១រូប |
| សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ១រូប |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ១រូប |
| សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ | ២រូប |
| វាគ្មិនក្នុងទី៥ | ៣២រូប |
| **ឈ. វិស័យឯកជន** | **១៤រូប** |
| ធនាគារអេស៊ីលីដា | ២រូប |
| Archetype | ១រូប |
| សមាគមស្ថាបត្យករនៃកម្ពុជា | ២រូប |
| សមាគមអ្នកសាងសង់កម្ពុជា | ២រូប |
| ក្រុមហ៊ុនលក់អចនទ្រព្យកម្ពុជា (CBRE) | ៣រូប |
| សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា | ១រូប |
| សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា | ២រូប |
| ក្រុមហ៊ុន WorldBridge Group | ១រូប |
| **ញ. ប្រព័ន្ធផ្សព្វផ្សាយ** | **២រូប** |
| ទូរទស្សន៍អប្សរា | ១រូប |
| ទូរទស្សន៍បាយ័ន | ១រូប |
| **សរុប** | **៣០០រូប** |

# ឧបសម្ព័ន្ធ ៣៖ រូបថត

## ការចុះឈ្មោះ





## អ្នកចូលរួម



## វគ្គអំពីការបើកវេទិកា










## វេទិកាជាតិលើកទី២ ស្តីពី
## “ទីក្រុង និងលំនៅឋាន”

<u>វគ្គទី២</u>






<u>វគ្គទី៣</u>









វគ្គទី៤




វគ្គទី៥

## វេទិកាជាតិលើកទី២ ស្តីពី
## “ទីក្រុង និងលំនៅឋាន”






<u>វគ្គបិទវេទិកា</u>












<u>កិច្ចប្រជុំសម្តែងការគួរសមជាមួយឧបនាយករដ្ឋមន្ត្រី</u>





# ឧបសម្ព័ន្ធ ៤៖ ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ




AMS Central (តំណភ្ជាប់)




អង្គការសហប្រជាជាតិប្រចាំកម្ពុជា (តំណភ្ជាប់)




ទូរទស្សន៍បាយ័នកម្ពុជា (តំណភ្ជាប់)




គេហទំព័ររបស់ UN-Habitat (តំណភ្ជាប់)

# ឧបសម្ព័ន្ធ ៥៖ សេចក្តីប្រកាសព័ត៌មាន៖ វេទិកាជាតិលើកទី២ ស្តីពី "ទីក្រុង និងលំនៅឋាន"

**រាជធានីភ្នំពេញ ថ្ងៃទី ៣០-៣១ ខែឧសភា ឆ្នាំ២០២៤៖** ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងកិច្ចសហការជាមួយធនាគារពិភពលោក និងកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UN-Habitat) បានរៀបចំវេទិកាជាតិលើកទី២ ស្តីពីទីក្រុងនិងលំនៅឋាន ក្រោមមូលបទ "ទីក្រុងឆ្លាត បៃតង មានភាពធន់ និងប្រកបដោយបរិយាបន្ន"។ វេទិកានេះបានប្រមូលផ្តុំនូវជំនាញការទីក្រុងនិងលំនៅឋានជាតិនិងអន្តរជាតិ និងមានការចូលរួមពីតំណាងស្ថាប័នជាតិ វិស័យឯកជន ស្ថាប័នអប់រំសិក្សាធិការ អ្នកជំនាញវ័យក្មេង និងតួអង្គមកពីអង្គការសង្គមស៊ីវិល សរុបជាង ២០០រូប ដើម្បីពិភាក្សាអំពីបញ្ហាប្រឈម និងបទពិសោធន៍នានាពាក់ព័ន្ធនឹងនគរូបនីយកម្មនិងការអភិវឌ្ឍលំនៅឋាន សម្រាប់តម្រង់ទិសការអភិវឌ្ឍទីក្រុងនាអនាគតរបស់យើងតាមរបៀបមួយដែលកាន់តែឆ្លាត បៃតង ចីរភាព និងមានបរិយាបន្នដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគ្រប់វ័យ។

វេទិកានេះបានធ្វើឡើងក្រោមអធិបតីភាពរបស់ឯកឧត្តម សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ឯកឧត្តម សាយ សំអាល់ បានបញ្ជាក់ថា *"យើងត្រូវរៀបចំទីក្រុងរបស់យើងប្រកបដោយចីរភាព និងបរិយាបន្នសម្រាប់ប្រជាពលរដ្ឋគ្រប់គ្នារស់នៅដោយរីករាយ ដែលក្នុងនោះរក្សាបាននូវវប្បធម៌ អរិយធម៌ និងទំនៀមទម្លាប់"*។ លើសពីនេះ ឯកឧត្តមបានបន្ថែមថាកម្ពុជាត្រូវបញ្ចូលគំនិតឆ្នៃប្រឌិតផ្សេងៗពីគ្រប់ភាគីពាក់ពន្ធ័ដើម្បីរួមគ្នាកសាងកម្ពុជាឱ្យស្មើមុខស្មើមាត់នៅក្នុងតំបន់ និងឱ្យក្លាយទៅជាប្រទេសប្រកបដោយចីរភាព និងបរិយាបន្នសម្រាប់ប្រជាជនកម្ពុជា និងប្រជាជនមកពីប្រទេសផ្សេងទៀតជុំវិញពិភពលោកអាចមករស់នៅបានដោយសុខដុមរមនានៅកម្ពុជា។

គួរបញ្ជាប់ផងដែរថា ប្រទេសកម្ពុជាបាន និងកំពុងជួបប្រទះកំណើននគរូបនីយកម្មយ៉ាងឆាប់រហ័ស ហើយតាមការព្យាករណ៍បង្ហាញថា ជាង៤០ភាគរយនៃចំនួនប្រជាជននឹងរស់នៅក្នុងតំបន់ទីប្រជុំជននៅឆ្នាំ២០៥០។ ការអភិវឌ្ឍនគរូបនីយកម្មដែលមិនមានផែនការជាមុន រួមមានដូចជាលំនៅឋានបណ្តោះអាសន្ន អាចបង្កឱ្យមានបញ្ហាបរិស្ថាន និងសង្គមផ្សេងៗ ដោយសារការប្រើប្រាស់ ឬយន្តការគ្រប់គ្រងដីធ្លីមិនសមស្រប និងមិនបានគ្រោងទុក។ ដូច្នេះ ការរៀបចំផែនការជាមុន និងអន្តរាគមន៍របស់រដ្ឋាភិបាល សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាកម្មកាន់តែប្រសើរ នឹងក្លាយជាគន្លឹះក្នុងការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព និងបរិយាបន្ន ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់រូប។

ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត បេងហុង សុជាតិ ខេមរ៉ូ អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម បានសង្កត់ធ្ងន់ថា អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និងអគ្គនាយកដ្ឋានលំនៅឋាន នឹងគាំទ្រក្រុង និង ទីប្រជុំជននានា ក្នុងការរៀបចំប្លង់គោលសំដៅសម្រេចឱ្យបានការអភិវឌ្ឍន៍ប្រកបដោយចីរភាពនាពេលអនាគត ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមាននៃនគរូបនីយកម្ម ស្របតាមការណែនាំរបស់ ឯកឧត្តម លោក សាយ សំអាល់ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

តាមរយៈបទបង្ហាញរបស់លោក Andre A. Bald អ្នកជំនាញនគរូបនីយកម្មរបស់ធនាគារពិភពលោក បានសង្កត់ធ្ងន់ថានគរូបនីយកម្មអាចដើរតួនាទីវិជ្ជមានក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រសិនបើមានការគ្រប់គ្រងល្អ និងការចូលរួមពីភាគីពាក់ព័ន្ធគ្រប់គ្រាន់។

វេទិកាជាតិលើកទី២ ស្តីពី

"ទីក្រុង និងលំនៅឋាន"

លោក សុខ វណ្ណា ប្រធានកម្មវិធី UN-Habitat នៅកម្ពុជា ក៏បានចែករំលែកបទពិសោធន៍ និងការប្តេជ្ញាចិត្តរបស់ UN-Habitat ក្នុងការគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីដោះស្រាយបញ្ហានគរូបនីយកម្ម និងការអភិវឌ្ឍលំនៅឋាន តាមរយៈការផ្តល់ជំនួយបច្ចេកទេស ដើម្បីធានាឱ្យបានការអភិវឌ្ឍទីក្រុងឆ្លាតវៃ បៃតង ប្រកបដោយចីរភាព និងបរិយាបន្ន។ សារៈសំខាន់នៃអភិក្រមអភិវឌ្ឍដោយផ្តោតលើប្រជាពលរដ្ឋក៏ត្រូវបានគូសបញ្ជាក់ផងដែរ ដើម្បីបង្កើនការចូលរួម និងសម្រេចលទ្ធផលប្រកបដោយចីរភាព។

ក្នុងការបិទវេទិកា លោក Joseph Scheuer អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាពដែលផ្តោតលើប្រជាពលរដ្ឋ តាមរយៈការពង្រឹងប្រសិទ្ធភាពភាពភាពដៃគូរវាងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីអភិវឌ្ឍទីប្រជុំជន និងលំនៅឋានរបស់ប្រជាពលរដ្ឋប្រកបដោយចីរភាពសម្រាប់ទាំងអស់គ្នា។ លោកក៏បានចែករំលែកយុទ្ធសាស្ត្រចំនួនបួនសំខាន់ៗដើម្បីលើកកម្ពស់ការអភិវឌ្ឍទីក្រុងឆ្លាត បៃតង ចីរភាព និងប្រកបដោយបរិយាបន្នៈ (១) អភិបាលកិច្ចទីក្រុង ការរៀបចំផែនការ និងការគ្រប់គ្រង (២) ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មប្រកបដោយភាពធន់ (៣) ដីធ្លី និងលំនៅឋានតម្លៃសមរម្យ និង (៤) ទីក្រុងប្រកបដោយភាពច្នៃប្រឌិត និងទិន្នន័យឆ្លាត។

ឯកឧត្តម តឹករ៉េត សំរេច រដ្ឋលេខាប្រចាំការ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានសង្កត់ធ្ងន់ថា វេទិកាជាតិលើកទី២ ស្តីពី "ទីក្រុង និងលំនៅឋាន" គឺជាឱកាសដ៏សំខាន់ក្នុងការជំរុញការពិភាក្សារវាងភាគីពាក់ព័ន្ធនានា ដើម្បីពិចារណា និងកំណត់ដំណោះស្រាយសមស្រប និងមានសក្តានុពល ឆ្លើយតបនឹងបញ្ហាប្រឈមដែលកម្ពុជាកំពុងជួបប្រទះ ដោយសារការអភិវឌ្ឍនគរូបនីយកម្ម និងលំនៅឋាននាពេលបច្ចុប្បន្ន ។

ថតរូបដោយ៖

អង្គការ UN-Habitat ប្រចាំនៅកម្ពុជា (ទំព័រមុខ  ទំព័រ ii, vii, ៦, ៩, ១២ (ខាងក្រោម), ១៦, ១៧, ១៩ (ខាងក្រោម), ២០ (ខាងលើ), ២៩, ៣០)
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ទំព័រ ២, ៤, ៥, ៧, ៨, ១០, ១១, ១២ (ខាងលើ), ១៣, ១៤, ១៥, ១៨, ១៩ (ខាងលើ), ២០ (ខាងក្រោម), ២៦, ២៧, ២៨, ២៩, ៣០)